# ជីវប្រវត្តិរបស់

# អ៊ីម៉ាំ អាលី صلوات الله عليه والسلام




សៃយីដ្ ម៉ាស់ូឌី អាយ៉ាទុលឡ៍ហ៊ី

ស្ហាគីប បេនបេឌីរ៉ា

بسم الله الرحمن الرحيم

# បញ្ជីមាតិកា


១-កំណើតនិងយុវភាព ........ 4

កំណើត ........ 4

ក្រោមម្លប់ព្រះសាស្ដាصلى الله عليه وآله وسلم ........ 5

យុវជនបម្រើអ៊ីស្លាម ........ 6

ទំព័រសីលធម៌របស់អ៊ុាលីصلوات الله عليه والسلام ........ 10

២-ក្រោយពីបណ្ដាំនៅក៏ុឌៀរ-ឃុម ........ 13

ការបង្ហើយសាសនា ........ 13

ឧត្តរាធិការ ........ 15

៣-រដ្ឋាភិបាលរបស់ព្រះអគ្គមហាប្រមុខរបស់មុស្លីម ........ 19

អ៊ុាលីប្រឈមនឹងពួកបះបោរ ........ 19

ទុក្ករកម្មរបស់អ៊ុាលីصلوات الله عليه والسلام ........ 21

សម្រង់សីលធម៌ត្រចះត្រចង់របស់អ៊ុាលីصلوات الله عليه والسلامក្នុងទំព័រប្រវត្តិសាស្ត្រ ........ 24

៤-គួយ៉ាងសុក្រឹតរបស់យុត្តិធម៌ ........ 26

១-អ៊ីម៉ាំរបស់ជនក្រីក្រ ........ 26

២-ការលុបបំបាត់ឯកសិទ្ធិ ........ 28

សម្រង់ព្រះវចនៈត្រចះត្រចង់ ........ 30

អត្តសញ្ញាណរបស់អ៊ីម៉ាំصلوات الله عليه والسلام ........ 30

# ១-កំណើតនិងយុវភាព

## កំណើត

ថ្ងៃសុក្រទី ១៣ ខែរ៉យ៉ាប់ ឆ្នាំទី ២៣ មុនសករាជហ៊ិច្រ៉ោះត៍ ទារកមួយរូបបានប្រសូតឡើងនៅក្នុងគ្រួសារអាប៊ូ ត៉ូលិប។ ទារកនេះបានបំភ្លឺម៉ាក់កាស្ហ៍និងភពផែនដែនចក្រវាលទាំងមូល។

ព្រឹត្តិការណ៍នេះបានកើតឡើងកាលអ៊ាប់បាស់ ឪពុកមារបស់ព្រះសាស្តា صلى الله عليه وآله وسلم កំពុងអង្គុយជាមួយបុរសគូរ៉យ៉ស្ហ៍ម្នាក់ទៀតនៅក្បែរកាក់បាស្ហ៍។ បុរសទាំងពីរនាក់បានឃើញនារីបានី-ហ្ហាស៊ីមម្នាក់មកកាន់កាក់បាស្ហ៍ គឺហ្វាទីម៉ាស្ហ៍ បុត្រីរបស់អាសាដ្ហ៍(فاطمة بنت أسد) ភរិយារបស់អាប៊ូ ត៉ូលិប(ابو طالب)។

ហ្វាទីម៉ាស្ហ៍បានធ្វើពិធីដើរឆ្វេលកាក់បាស្ហ៍ព្រមទាំងបួងសួងអល់ឡោះហ្ហ៍ عز وجل ដោយងើយមើលទៅឯលើមេឃ ថា៖ "*ព្រះម្ចាស់អើយ! ខ្ញុំម្ចាស់ជឿព្រះអង្គ عز وجل, ជឿព្រះសាស្តា عليهم السلام ទាំងអស់ عز وجل,និងព្រះគម្ពីរទាំងអស់ដែលព្រះអង្គ عز وجل,បានចាត់បញ្ជូនមក ។ ទូលព្រះបង្គំជាខ្ញុំម្ចាស់ជឿព្រះវចនៈទាំងអស់របស់អ៊ិបរ៉ហ៊ីម ព្រះបុព្វបុរសរបស់ខ្ញុំម្ចាស់ដែលបានសាងសង់ព្រះមហាគ្រឹះស្ថានបុរាណនេះ ។ ក្នុងនាមនៃឯកសិទ្ធិរបស់បុគ្គលដែលបានសាងសង់ព្រះមហាគ្រឹះស្ថាននេះ ក្នុងនាមនៃឯកសិទ្ធិរបស់ទារកដែលនៅក្នុងផ្ទៃទូលព្រះបង្គំជាខ្ញុំម្ចាស់នេះ សូមព្រះអង្គ عز وجل,មេត្តាជួយឲ្យទូលព្រះបង្គំជាខ្ញុំម្ចាស់ប្រសូតបុត្រមកដោយងាយស្រួលផង!*"

នៅទីនេះ ទិដ្ឋភាពអស្ចារ្យមួយបានកើតឡើងគឺ៖ អល់ឡោះហ្ហ៍ عز وجل,បានធ្វើឲ្យស្ត្រីមានសទ្ធាជ្រះថ្លារូបនេះសមបំណង ហើយឲ្យមានក្រហែងនៅលើជញ្ជាំងកាក់បាស្ហ៍បើកឡើងដើម្បីឲ្យស្ត្រីមានជំនឿស៊ប់ចិត្តរូបនេះចូលទៅខាងក្នុង រួចហើយបិទជិតវិញភ្លាម។

ភ័យរន្ធត់ដោយសារទិដ្ឋភាពនេះ អ៊ាប់បាស់បានរត់ទៅរកពួកបានី-ហ្ហាស៊ីមដើម្បីសូមជំនួយពីនារីពីរបីនាក់។ ដំណឹងនេះបានលេចឮពេញនគរម៉ាក់កាស្ហ៍។ មនុស្សសន្ធឹកសន្ធាប់បានចោមរោមកាក់បាស្ហ៍ហើយបានឆ្វេលជុំវិញកាក់បាស្ហ៍តែមិនអាចចូលទៅខាងក្នុងនោះបានទេ។

មនុស្សទូទៅភ័យរន្ធត់។ គេបានរង់ចាំអស់បួនថ្ងៃទើបឃើញហ្វាទីម៉ាស្ហ៍ចេញមកវិញ បីកូនទើបនឹងប្រសូតក្នុងដៃ។ មនុស្សម្នាសួរគ្នាថាតើទារកដ៏រុងរឿងនេះមាននាមអ្វីទៅ ហ្វាទីម៉ាស្ហ៍បានថា៖ "*ឈ្មោះអាលី صلوات الله عليه والسلام! នៅក្នុងព្រះមហាគ្រឹះស្ថានរបស់អល់ឡោះហ្ហ៍ عز وجل, ខ្ញុំបានឮសម្លេងមួយចេញមកពីកន្លែងអាថ៌កំបាំង បញ្ជាឲ្យខ្ញុំហៅទារកនេះថាអាលី صلوات الله عليه والسلام ។*"

មូហាំម៉ាដ្ហ៍ صلى الله عليه وآله وسلم បានយកអាលី صلوات الله عليه والسلام មកចិញ្ចឹម។ អាលី صلوات الله عليه والسلام មានភ័ព្វសំណាងណាស់ដែលមានគ្រូបាធ្យាយនិងអាណាព្យាបាលប្រសើរបំផុតក្នុងភពផែនដែនចក្រវាល។ នៅក្នុងសុន្ទរកថាល្បីល្បាញរបស់ព្រះអង្គ صلوات الله عليه والسلام មួយ អាលី صلوات الله عليه والسلام បានតំណាលប្រាប់យើងនូវចំណុចពាក់ព័ន្ធនឹងជីវិតរស់នៅមួយចំនួនអាស្រ័យឯកសិទ្ធិដ៏ធំធេងនេះ។ ត្រង់នេះយើងលើកយកមកតែមួយចំណុចគឺ សេចក្តីថ្នាក់ថ្នមទន់ភ្លន់ផ្អែមល្ហែមនិងចិត្តសប្បុរសដែលអាលី

صلوات الله عليه والسلامបានស្គាល់កាលពីនៅវ័យកុមារ និងសេចក្ដីប្រយ័ត្នប្រយែងផ្ចិតផ្ចង់ពិសេសដែលព្រះអាណាព្យាបាលصلى الله عليه وآله وسلم របស់ព្រះអង្គصلوات الله عليه والسلامមានមកលើរូបព្រះអង្គصلى الله عليه وآله وسلمនោះធំធេងក្រៃលែង និងខុសធម្មតាក្នុងចំណោមពួកអារ៉ាប់នាសម័យនោះ។

## ក្រោមម្លប់ព្រះសាស្ដាصلى الله عليه وآله وسلم

ចាប់តាំងពីអាយុប្រាំមួយឆ្នាំមកម្ល៉េះ អ៊ាលីصلوات الله عليه والسلامមិនដែលឃ្លាតពីមូហាំម៉ាដ់صلى الله عليه وآله وسلمទេ ដែលជាអាណាព្យាបាល និងគ្រូរបស់ព្រះអង្គصلوات الله عليه والسلامនោះ។ ព្រះអង្គصلوات الله عليه والسلامតែងតែតាមព្រះសាស្ដាصلى الله عليه وآله وسلم ដូចស្រមោលអន្ទោលតាមប្រាណ។ រៀងរាល់ថ្ងៃ ព្រះអង្គصلوات الله عليه والسلامស្រង់យកនូវសីលធម៌ដ៏ថ្លៃថ្នូរ ព្រះអភិញ្ញានិងព្រះប្រាជ្ញាញាណរបស់ព្រះសាស្ដាصلى الله عليه وآله وسلم។

រៀងរាល់ឆ្នាំ ព្រះអង្គصلوات الله عليه والسلامទៅឯគុហាហ៊ីរ៉អ៊ុ(حراء)ជាមួយព្រះសាស្ដាصلى الله عليه وآله وسلم ហើយព្រះអង្គصلوات الله عليه والسلامជាមនុស្សម្នាក់គត់ដែលបានឃើញព្រះសាស្ដាصلى الله عليه وآله وسلمសន្ទនាជាមួយព្រះម្ចាស់عز وجلរបស់ព្រះអង្គឱ្យច។ អស់មួយរយៈពេល មានតែអ៊ាលីصلوات الله عليه والسلام ខ៌ឌីយ៉ាស់سلام الله عليهاនិងព្រះសាស្ដាصلى الله عليه وآله وسلمទេជាមុស្លីម ហើយមានតែនៅក្នុងផ្ទះរបស់អ្នកទាំងបីعليهم السلامទេដែលគេគោរពបូជាអល់ឡោះហ៍عز وجلនោះ។

លុះអល់ឡោះហ៍عز وجلបានបញ្ជាឲ្យព្រះសាស្ដាصلى الله عليه وآله وسلمព្រះអង្គعز وجلដាស់តឿនគ្រួសារធំរបស់ព្រះអង្គصلى الله عليه وآله وسلم ហើយឲ្យព្រះអង្គصلى الله عليه وآله وسلمកោះហៅពួកគេមកកាន់សាសនាអ៊ីស្លាម ព្រះសាស្ដាصلى الله عليه وآله وسلمបានចាត់ឲ្យអ៊ាលីរៀបចំអាហារលៀងភ្ញៀវសែសិបនាក់ និងឲ្យអញ្ជើញសាច់ញាតិបានី-ហ្ជាស៊ីម ជាពិសេសឪពុកមាទាំងឡាយរបស់ព្រះអង្គصلى الله عليه وآله وسلمគឺ អាប៊ូត៉លិប (ابو طالب) អ៊ាប់បាស់(عباس) ហាំស្សាស់(حمزة) និងអាប៊ូ ឡាហ្ជាប់(أبو لهب)។

លុះភ្ញៀវបានមកជុំគ្នាហើយ ព្រះសាស្ដាصلى الله عليه وآله وسلمបានប្រកាសថា៖ "*កូនចៅអ៊ាប់ឌុល-មុត្ដត៉លិប*(عبد المطلب)*អើយ! ខ្ញុំ*صلى الله عليه وآله وسلم*មិនស្គាល់យុវជនអារ៉ាប់ណាទេ ដែលអាចនាំមកឲ្យប្រជារាស្ត្ររបស់ខ្លួននូវអ្វីដែលល្អប្រសើរបំផុតលើសអ្វីដែលខ្ញុំ*صلى الله عليه وآله وسلم*នាំមកនេះ គឺ៖ ខ្ញុំ*صلى الله عليه وآله وسلم*នាំមកឲ្យអស់លោកនូវសម្បត្តិនៃលោកនេះនិងលោកមុខ! អល់ឡោះហ៍ ព្រះដ៏មហាខ្ពង់ខ្ពស់ បានដាក់ព្រះបញ្ជាមកលើខ្ញុំ*صلى الله عليه وآله وسلم *ឲ្យខ្ញុំ*صلى الله عليه وآله وسلم*ហៅអស់លោកមករកព្រះអង្គ*عز وجل! *ដូច្នេះ អ្នកណា ក្នុងចំណោមអស់លោក ស្ម័គ្រចិត្តជួយខ្ញុំ*صلى الله عليه وآله وسلم*និងគាំទ្រខ្ញុំ*صلى الله عليه وآله وسلم*ក្នុងបេសកកម្មនេះ អ្នកនោះជាបងប្អូនខ្ញុំ*صلى الله عليه وآله وسلم *ជាអ្នកស្នងខ្ញុំ*صلى الله عليه وآله وسلم*ពេលអត់ពីខ្ញុំ*صلى الله عليه وآله وسلم *និងជាអ្នកបំពេញតាមបណ្ដាំខ្ញុំ*صلى الله عليه وآله وسلم *។*"

ទាំងអស់គ្នាបានថយក្រោយ។ ឪពុកមាមួយចំនួនរបស់ព្រះសាស្ដាصلى الله عليه وآله وسلمបានប្រព្រឹត្តមិនសមគួរមកលើក្មួយខ្លួន។ មានតែអ៊ាលីصلوات الله عليه والسلامម្នាក់ទេដែលលើកដៃ ហើយថា៖ "*ព្រះសាស្ដា*صلى الله عليه وآله وسلم*អល់ឡោះហ៍*عز وجل*អើយ ទូលបង្គំជាដៃស្ដាំរបស់ព្រះអង្គ*صلى الله عليه وآله وسلم*ក្នុងបេសកកម្មនេះ ។*"

មូហាំម៉ាដ់صلى الله عليه وآله وسلمមានព្រះវចនៈថា៖ "*បុរសរូបនេះជាបងប្អូនរបស់ខ្ញុំ*صلى الله عليه وآله وسلم *ជាអ្នកបំពេញតាមបំណងខ្ញុំ*صلى الله عليه وآله وسلم *និងជាអ្នកស្នងខ្ញុំ*صلى الله عليه وآله وسلم*ក្នុងចំណោមអស់លោក ។ ដូច្នេះ ចូរអស់លោកស្ដាប់គេនិងស្ដាប់ឱវាទគេ!*"

យោលតាមសេចក្ដីរាយការណ៍ទៀងត្រង់ កាលនោះអ៊ាលីصلوات الله عليه والسلامមានអាយុមិនលើសពីដប់ឆ្នាំទេ សឲ្យឃើញថាព្រះអង្គصلوات الله عليه والسلامមានគុណសម្បត្តិខ្ពង់ខ្ពស់សម្រាប់អល់ឡោះហ៍عز وجل ព្រោះព្រះសាស្ដាصلى الله عليه وآله وسلمពិតជាមិនមែន

បុគ្គលដែលប្រគល់កិច្ចការសំខាន់ឲ្យទៅក្មេងវ័យប៉ុណ្ណោះនោះទេ ប្រសិនបើអល់ឡោះហ៍ ព្រះទ្រង់ញាណសព្វសារពើ ព្រះដែលដឹងព្រឹត្តិការណ៍ក្នុងអនាគតកាលនោះ មិនបានដាក់ព្រះបញ្ជាមកឲ្យធ្វើបែបនេះទេនោះ។



## យុវជនបម្រើអ៊ីស្លាម

អ៊ាលីបានធាត់ធំនៅក្នុងលក្ខខណ្ឌប្រសើរ ដើម្បីបំពេញបេសកកម្មដែលត្រូវបានគ្រោងទុកសម្រាប់ព្រះអង្គនោះ។ ព្រះអង្គ صلوات الله عليه والسلام ជាសាវកភ័ក្តីរបស់ព្រះសាស្តា ﷺ និងជាអ្នកអនុវត្តិតាមបញ្ជាព្រះអង្គ ﷺ ឥតរួញរា។ ព្រះ

អង្គ صلوات الله عليه والسلام ជាយុវជនខ្លាំងក្លានិងបូជាខ្លួនបម្រើសាសនាអល់ឡោះហ៍ عز وجل និងបម្រើសាស្តា صلى الله عليه وآله وسلم ព្រះអង្គ عز وجل ។

យើងបានដឹងហើយថានៅក្នុងសមរភូមិសំខាន់ៗរបស់អ៊ីស្លាម អ៊ាលី صلوات الله عليه والسلام ជាយុទ្ធជនបូជាខ្លួននិងមិនដែលបរាជ័យទេ ។ វីរបុរសល្បីៗរលំដួល ព្រះអង្គ صلوات الله عليه والسلام រឹងជំហរជានិច្ច គ្មាននរណាប៉ះពាល់ព្រះអង្គ صلوات الله عليه والسلام បានឡើយ ។ យើងរំលឹកឡើងវិញនូវគំរូមួយចំនួនគឺ៖

-សមរភូមិហ៊ូណៃន៍(حنين) ការប្រយុទ្ធតស៊ូរបស់អ៊ាលី صلوات الله عليه والسلام បាននាំជ័យជំនះយ៉ាងត្រចះត្រចង់មកឲ្យភាគីមុស្លីម បន្ទាប់ពីស្ថានថាទទួលបរាជ័យហើយនោះ ។



-ការវាយយកបានខ៊ុយ៉បារ(خيبر) បន្ទាប់ពីមូលដ្ឋានទ័ពយ៉ាហ៊្វូឌីបានតស៊ូ និងបន្ទាប់ពីមេបញ្ជាការមុស្លីមទាំងឡាយដែលត្រូវចាត់បញ្ជូនមកមុនអ៊ាលី صلوات الله عليه والسلام នោះបានទទួលបរាជ័យ... ការវាយយកបាននេះបានធ្វើឲ្យភាគីមុស្លីមចៀសផុតពីផែនការអាក្រក់របស់ពួកយ៉ាហ៊្វូឌីនៃឧបទ្វីបអារ៉ាប់ និងរួចផុតពីការពឹងពាក់គេក្នុងរឿងថវិកាដែលផ្អែកទៅលើពួកព្រឹទ្ធិករ។

យើងមិនភ្លេចឡើយចំណុចអង់អាចក្លាហាននៃការប្រយុទ្ធតស៊ូរបស់អ៊ាលី صلوات الله عليه والسلام នៅឯខ៊ុយ៉បារនោះ។ តើព្រះអង្គ صلوات الله عليه والسلام មិនបានកន្ត្រាក់ទ្វារបន្ទាយដែលធំនិងធ្ងន់ដោយដៃព្រះអង្គ صلوات الله عليه والسلام ទេ ដែលបុរសខ្លាំងជាងគេប្រាំពីរនាក់មិនអាចធ្វើឲ្យវាកម្រើកបានផងនោះ?

តែភាពអង់អាចក្លាហានមួយ ក្នុងចំណោមភាពអង់អាចក្លាហានទាំងឡាយរបស់អ៊ាលី صلوات الله عليه والسلام គឺការប្រឈមនឹងសេចក្តីស្លាប់ជួសព្រះសាស្តា صلى الله عليه وآله وسلم នាយប់ដែលព្រះអង្គ صلى الله عليه وآله وسلم ភៀសខ្លួននោះជិតជាប់នៅក្នុងអារម្មណ៍យើងជានិច្ច។ យើងចាំបានយ៉ាងច្បាស់ថាភាគីគូរ៉យ៉ស្ហ៍បានចាត់ឲ្យកុលសម្ព័ន្ធនីមួយៗបញ្ជូនយុទ្ធជនម្នាក់មកសម្លាប់ព្រះសាស្តា صلى الله عليه وآله وسلم ក្នុងយប់នោះ ពួកឃាតករទាំងនេះបានភ្ញាក់ផ្អើល ក្រោយពីបានរង់ចាំយ៉ាងយូរ ដែលបានឃើញអ៊ាលី صلوات الله عليه والسلام ផ្ទំនៅក្នុងគ្រែមូហាំម៉ាដ្ឋ صلى الله عليه وآله وسلم ហើយពួកគេបានរត់ប្រាស់អាយុពេលអ៊ាលី صلوات الله عليه والسلام លោតចេញពីគ្រែប្រុងខ្លួនប្រយុទ្ធ។

អ៊ាលី صلوات الله عليه والسلام ជាយុទ្ធជនដ៏អស្ចារ្យបំផុតដែលនៅខាងព្រះសាស្តា صلى الله عليه وآله وسلم អល់ឡោះហ៊្វ عز وجل។ ដាវព្រះអង្គ صلوات الله عليه والسلام ជាដាវដំបូងបង្អស់របស់អ៊ីស្លាម។ មួយជីវិតព្រះអង្គ صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام បានបម្រើកិច្ចការនានាដែលមានតែអល់ឡោះហ៊្វ عز وجل និងព្រះសាស្តា صلى الله عليه وآله وسلم ព្រះអង្គ عز وجل ទេអាចកាត់ថ្លៃបាន។

តែមិនត្រូវឲ្យយុវភាពរបស់អ៊ាលី صلوات الله عليه والسلام ដែលប្រកបដោយលក្ខណៈប្រយុទ្ធតស៊ូនោះ បិទបាំងការពិតដ៏សំខាន់នោះទេគឺ៖ សាសនាអ៊ីស្លាមកំពុងតែស្ថិតនៅក្នុងស្ថានភាពមួយដែលតម្រូវឲ្យធ្វើសង្គ្រាមជាចាំបាច់។ អ្នកមានជំនឿទាំងអស់ត្រូវតែខិតខំប្រឹងប្រែងចូលរួមតាមសមត្ថភាពខ្លួន។ ដូច្នេះមិនមែនកម្លាំងកាយអ៊ាលី صلوات الله عليه والسلام នោះទេដែលបានធ្វើឲ្យការប្រយុទ្ធរបស់អ៊ីស្លាមនោះជាការប្រយុទ្ធអបរាជ័យ តែភ័ក្តីភាពនិងសេចក្តីស្រឡាញ់ឥតព្រំដែនចំពោះសាសនាអ៊ីស្លាម និងចំពោះប្រេសិតរបស់សាសនាអ៊ីស្លាមនោះទេដែលធ្វើការប្រយុទ្ធនោះអបរាជ័យ។

ពិតណាស់ ភ័ក្តីភាពតម្រូវឲ្យអ្នកមានសទ្ធាគ្រប់រូបទៅជាយុទ្ធជនជំនាញពីព្រោះភាគីមុស្លីមចាំបាច់ត្រូវតស៊ូដោយមធ្យោបាយយោធា។ នេះគឺលក្ខណៈពិសេសទូទៅរបស់គ្រប់សង្គ្រាមការពារខ្លួន ហើយអ្វីដែលប្រចក្សនោះគឺ សមរភូមិទាំងអស់របស់ព្រះសាស្តា صلى الله عليه وآله وسلم ជាសមរភូមិការពារខ្លួន។

ម្យ៉ាងទៀត យើងបានដឹងហើយថាហេតុអ្វីបានជាព្រះសាស្តា صلى الله عليه وآله وسلم បានជ្រើសរើសអ៊ាលី صلوات الله عليه والسلام ក្នុងចំណោមសាវកទាំងអស់របស់ព្រះអង្គ صلى الله عليه وآله وسلم នោះ ដើម្បីជួយគាំទ្រព្រះអង្គ صلى الله عليه وآله وسلم ក្នុងរដ្ឋាភិបាលម៉ាឌីណាស្ហ៍ ក្នុងគ្រាដែលពួកពុតត្បុតធ្វើផែនការណ៍សម្ងាត់កាន់តែគ្រោះថ្នាក់ឡើងៗ។

ទាំងនេះសឲ្យឃើញថាអ៊ាលី صلوات الله عليه والسلام មិនត្រឹមតែជាអ្នកចម្បាំងប៉ុណ្ណោះទេ តែព្រះអង្គ صلوات الله عليه والسلام ជាមេដឹកនាំនយោបាយផងដែរដែលមានសមត្ថភាពស្នងព្រះសាស្តា صلى الله عليه وآله وسلم បានក្នុងស្ថានភាពលំបាក។

កិច្ចការទាំងឡាយដែលអ៊ាលី صلوات الله عليه والسلام បានធ្វើដើម្បីសាសនាអ៊ីស្លាម កាលព្រះអង្គ صلوات الله عليه والسلام នៅក្មេងនោះ មានសារសំខានបំផុតពីរដែលអាចពោលសង្ខេបបានដូចតទៅគឺ៖

សារសំខាន់បំផុតទីមួយ នៅក្នុងសមរភូមិខាន់ដាក់(الخندق) ឬសមរភូមិប្រឡាយ កាលព្រះអង្គ صلوات الله عليه والسلام បានកាត់ក្បាលវីរបុរសរបស់ភាគីពហុទេពនិយមទាំងមូល ដែលមានឈ្មោះថា អ៊ាំរ៉ូ អ៊ិបនូ អ៊ាប់ឌុល-វ៉ាដ់ ដែលយើងបានដឹងរួចមកហើយនោះ។



ព្រះសាស្តា ﷺ មានព្រះវចនៈកាលនោះថា៖ *"ការប្រយុទ្ធរបស់អ៊ាលី صلوات الله عليه والسلام នាថ្ងៃសមរភូមិប្រឡាយស្មើនឹងការគោរពបូជាអល់ឡោះហ៊ូ عز وجل,ដោយស្មោះអស់ពីចិត្តពីរលោកទាំងពីរ ។"*

មែន ការវាយប្រហារនោះជាការវាយផ្តាច់ក្បាលភាគីពហុទេពនិយម។ បន្ទាប់ពីការវាយប្រហារនេះ ភាគី

ពហុទេពនិយមបានដកថយជាចាំបាច់រហូតដល់បែកខ្ញែកអស់ទាំងស្រុង។

សារសំខាន់បំផុតទីពីរគឺ៖ នៅពេលត្រឡប់មកពីសមរភូមិមួយ យុទ្ធជនមុស្លីមម្នាក់ត្រូវព្រះសាស្តា صلى الله عليه وآله وسلم កាត់ទោសព្រោះតែបានប្រទូសប្រឆាំងមេបញ្ជាការអ៊ាលី صلوات الله عليه والسلام ។ ព្រះសាស្តា صلى الله عليه وآله وسلم មានព្រះវចនៈកាលនោះថា៖ "*សច្ចធម៌នៅជាប់នឹងអ៊ាលី صلوات الله عليه والسلام អ៊ាលី صلوات الله عليه والسلام នៅជាប់នឹងសច្ចធម៌ជានិច្ច ។*"

## ទំព័រសីលធម៌របស់អ៊ាលី صلوات الله عليه والسلام

គេមិនអាចថ្លែងអំពីយុវភាពរបស់អ៊ាលី صلوات الله عليه والسلام និងការបម្រើសាសនាអ៊ីស្លាមរបស់ព្រះអង្គ صلوات الله عليه والسلام ដោយចោលចរិយាសម្បត្តិរបស់ព្រះអង្គ صلوات الله عليه والسلام នោះបានទេ។ ចរិយាសម្បត្តិព្រះអង្គតែមួយប៉ែកនេះ صلوات الله عليه والسلام សុខុមនិងបរិបូរក្រៃពេក មួយវគ្គធំទើបពិព័ណ៌នាអធិប្បាយអស់។ សាវកភក្តីរូបនេះមានសីលធម៌ថ្លៃថ្នូរនិងស្មោះស្ម័គ្រភក្តីចំពោះព្រះសាស្តាចុងក្រោយបង្អស់។

ត្រង់នេះ យើងគ្រាន់តែបើកឲ្យឃើញនូវរស្មីចែងចាំងដ៏តូចមួយដែលអាចឆ្លុះបញ្ចាំងឲ្យយើងឃើញនូវពិភពគុណធម៌ដ៏ឧត្តុង្គឧត្តមរបស់អ៊ាលី صلوات الله عليه والسلام បាន។ គេឃើញមានគុណធម៌ដ៏ឧត្តុង្គឧត្តមនេះនៅក្នុងសមរភូមិដ៏សម្បើមនោះម្តងទៀត(ដែលហៅថាសមរភូមិប្រឡាយនោះ) នៅពេលប្រយុទ្ធតតួដដែលទល់នឹងអុំារូ អ៊ិបនូ អ៊ាប់ឌុល-វ៉ាដ៉ុ វីរបុរសរបស់ភាគីពហុទេពនិយមនោះ។

ពេលអុំារូ អ៊ីបនូ អ៊ាប់ឌុល-វ៉ាដ៉ុ បានវាយទម្លុះកងទ័ពស្រួចមុស្លីមជាមួយបក្សពួកខ្លួន បានបបួលយុទ្ធជនអ៊ីស្លាមប្រយុទ្ធតតួ បានសើចចំអកឲ្យខ្លួនពួកគេ និងភាពខ្លបខ្លាចពួកគេនោះ អ៊ាលី صلوات الله عليه والسلام បានស្ទុះទៅរកអុំារូ អ៊ីបនូ អ៊ាប់ឌុល-វ៉ាដ៉ុយ៉ាងរហ័សទាំងពិបាកចិត្តដោយសារតែព្រះអង្គ صلوات الله عليه والسلام មានភារកិច្ចទទួលខុសត្រូវ។ ព្រះសាស្តា صلى الله عليه وآله وسلم មានព្រះវចនៈសង្ខេបអំពីរឿងនេះថា៖ "*នេះគឺការប្រយុទ្ធរបស់ជំនឿទាំងមូលទល់នឹងលទ្ធិគ្មានសាសនា ។*"

ដោយបានឃើញយុវជនមួយរូបដើរចូលមករកខ្លួន អុំារូ អ៊ីបនូ អ៊ាប់ឌុល-វ៉ាដ៉ុបានប្រមាថអ៊ាលី صلوات الله عليه والسلام មិនព្រមប្រយុទ្ធទល់ព្រះអង្គ صلوات الله عليه والسلام ទេ ហើយថា៖ "*ឯងចេញទៅ! អញមិនចង់សម្លាប់ឯងទេ!*" តែវីរបុរសអ៊ីស្លាមបានឆ្លើយយ៉ាងម៉ឺងម៉ាត់ថា៖ "*តែខ្ញុំ صلوات الله عليه والسلام ចង់សម្លាប់អ្នកឯង ។*"

លុះអុំារូ អ៊ីបនូ អ៊ាប់ឌុល-វ៉ាដ៉ុបានរលំក្រោមការវាយប្រហាររបស់អ៊ាលី صلوات الله عليه والسلام ដេកនៅលើធូលី ឃើញគូប្រយុទ្ធរបស់ខ្លួនដើរចូលមកកាត់ក្បាលខ្លួន អុំារូ អ៊ីបនូ អ៊ាប់ឌុល-វ៉ាដ៉ុបានស្តោះទឹកមាត់ដាក់មុខអ៊ាលី صلوات الله عليه والسلام ។ គួរតែអ៊ាលី صلوات الله عليه والسلام បង្ហើយជីវិតបុរសអសទ្ធារូបនោះភ្លាមៗ ផ្ទុយទៅវិញ ព្រះអង្គ صلوات الله عليه والسلام បានឈប់មួយស្របក់ រង់ចាំឲ្យបាត់ក្រោធសិន បន្ទាប់ពីនោះទើបព្រះអង្គ صلوات الله عليه والسلام បង្ហើយជីវិតអុំារូ អ៊ីបនូ អ៊ាប់ឌុល-វ៉ាដ៉ុ។

នេះគឺមេរៀនសីលធម៌ដ៏ធំធេងមួយ ដែលគេមិនអាចនឹកស្មានដល់បាន។ មានតែបុគ្គលមិនចេះភាន់ច្រឡំទេដែលអាចគ្រប់គ្រងខ្លួនឯងបានដូច្នេះ និងអាចគ្រប់គ្រងកំហឹងខ្លួនឯងបាននៅពេលស្លាប់រស់ក្នុងការប្រយុទ្ធតតួនោះ។

ពេលគេបានសួរអ៊ាលី صلوات الله عليه والسلام ថាហេតុអ្វីព្រះអង្គ صلوات الله عليه والسلام មិនសម្លាប់គូប្រយុទ្ធព្រះអង្គ صلوات الله عليه والسلام ភ្លាមៗនោះ ព្រះអង្គ صلوات الله عليه والسلام បានតបថា ព្រះអង្គ صلوات الله عليه والسلام ចង់ឲ្យរូបព្រះអង្គ صلوات الله عليه والسلام ជឿជាក់យ៉ាងច្បាស់ថាមិនមែនដើម្បីសងសឹកទង្វើ

អប្រិយរបស់អ៊ាំរ្ង អ៊ីបនូ អ៊ាប់ឌុល-វ៉ាដ៉ុនោះទេដែលព្រះអង្គ صلوات الله عليه والسلام នឹងសម្លាប់គាត់នោះ។

នេះគឺសីលធម៌របស់បុគ្គលដែលមិនចេះភាន់ច្រឡំមែន ដែលមិនធ្វើអ្វីដើម្បីខ្លួនឯងទេ តែឧទ្ទិសជីវិតខ្លួន និងទង្វើគ្រប់ប្រការដើម្បីអល់ឡោះហ៊ូ عز وجل ។



ពេលនេះគេអាចយល់បានយ៉ាងងាយស្រួលថាព្រះសាស្ដាមិនបាននិយាយពន្លើសទេ កាលព្រះអង្គ صلى الله عليه وآله وسلم មានព្រះវចនៈថា៖ *"ការប្រយុទ្ធរបស់អ៊ាលី صلوات الله عليه والسلام នាថ្ងៃសមរភូមិប្រឡាយស្មើនឹងការគោរពបូជាអល់ឡោះហ៊ូ عز وجل, ដោយស្មោះអស់ពីចិត្តពីលោកទាំងពីរ(មនុស្សនិងអទិស្សមាន"យ៉ិន") ។"*

នោះមិនមែនការប្រយុទ្ធដើម្បីខ្លួនឯង ឬដើម្បីកិត្យានុភាពទេ តែដើម្បីសព្វព្រះហឫទ័យអល់ឡោះហ៍ عز وجل តែមួយគត់។ នេះឯងរស្មីចែងចាំងនោះ មិនលើសពីនេះទេ។ អាលី صلوات الله عليه والسلام ស្ថិតនៅក្នុងកម្រិតមហាត្បូននិងសីលធម៌ឧត្តុង្គឧត្តមនេះអស់មួយព្រះជន្មព្រះអង្គ صلوات الله عليه والسلام ។

មិនមែនជាការចៃដន់ទេដែលអល់ឡោះហ៍ عز وجل បានជ្រើសរើសអគ្គបុរសលំដាប់ថ្នាក់នេះ ដើម្បីស្នងព្រះបរមគ្រូរបស់សព្វសត្វលោក ព្រះសាស្តាចុងក្រោយបង្អស់នោះ។

ការពិត ការជ្រើសរើសនេះបានធ្វើឲ្យអាលី صلوات الله عليه والسلام ប្រឈមនឹងបញ្ហាដ៏លំបាកបំផុតមួយ ព្រោះពេលនេះមិនមែនប្រឈមមុខនឹងពួកអសទ្ធានោះទេ តែប្រឈមមុខនឹងពួកមុស្លីមនោះវិញ គឺមុស្លីមភាគច្រើនដែលរហូតមកដល់ពេលនេះតែងតែប្រយុទ្ធរួមជាមួយព្រះអង្គ صلوات الله عليه والسلام ទល់នឹងសត្រូវរួម។

# ២-ក្រោយពីបណ្តាំនៅគ៉ុំខ្មៀរ-ឃុម

## ការបង្ហើយសាសនា

បន្ទាប់ពីបានធ្វើពិធីធម្មយាត្រា(ពិធីហាច្ជ៍)លាគ្នា មានតែរឿងស្នងតំណែងទេដែលធ្វើឲ្យព្រះសាស្តាﷺ បារម្ភ។ ពិតណាស់ ព្រះអង្គﷺបានទទួលដំណឹងពីអល់ឡោះហ៍عز وجلថាព្រះអង្គﷺជិតចូលទិវង្គតហើយ ព្រះអង្គﷺបានឃើញផងដែរថាមានអ្នកតាមសាសនាអ៊ីស្លាមច្រើនរយពាន់នាក់នៅគ្រប់ទិសទាំងបួននៃឧបទ្វីបអារ៉ាប់។

ព្រះអង្គﷺបានឃើញដែរនូវច្រើនផលអាក្រក់ដំបូងនៃការបកស្រាយ ឃើញការទេរទៅរកភាពវៀចវេរចាប់ផ្តើមលេចឡើង ហើយឃើញពួកពុតត្បុតចាប់ផ្តើមប្រព្រឹត្តអំពើហិង្សាបន្តិចម្តងៗមកលើសាសនាអ៊ីស្លាមនិងមកលើព្រះសាស្តាអល់ឡោះហ៍عز وجل។

អ្វីទាំងនេះធ្វើឲ្យព្រះសាស្តាﷺបារម្ភឥតស្រាក។ អ្នកស្នងតំណែងត្រូវតែមានជំហរទ្រាំទ្រភារកិច្ចនេះ បានត្រូវមានលក្ខខណ្ឌសីលធម៌ត្រឹមត្រូវនិងមានសមត្ថិភាពស្រដៀងព្រះអង្គﷺដែរ។ មានតែបុគ្គលម្នាក់ទេដែលមានគុណសម្បត្តិទាំងនេះ គឺអាលីصلوات الله عليه والسلام។

តែមេគ្រួរ៉យស្ស៍ដែលទើបនឹងបានផ្លាស់សាសនាមកកាន់សាសនាអ៊ីស្លាមនោះ ដែលពាំទុកនូវគំនុំឥតភ្លេចបាន ចំពោះរូបអាលីصلوات الله عليه والسلامដែលបានសម្លាប់បងប្អូនពួកគេក្នុងសមរភូមិនានានោះ នឹងព្រមទទួលការតែងតាំងអាលីصلوات الله عليه والسلامទេ ?

បណ្តាសាវកមុនៗរបស់ព្រះសាស្តាﷺដែលបានមកកាន់សាសនាអ៊ីស្លាមក្រោយអាលីصلوات الله عليه والسلامនោះ មានវ័យចាស់ជាងអាលីصلوات الله عليه والسلام ពួកគេមួយចំនួនសង្ឃឹមស្នងតំណែង។ តើពួកគេនឹងព្រមទទួលការតែងតាំងអាលីصلوات الله عليه والسلامដែរទេ ?

ម្យ៉ាងទៀត សម័យនោះ អាលីصلوات الله عليه والسلامមានព្រះជន្មតែសាមសិបបីឆ្នាំទេ ចំណែកឯសាវកមួយចំនួនរបស់ព្រះសាស្តាﷺមានអាយុលើសហុកសិបឆ្នាំ។

សញ្ញាសំគាល់ទាំងនេះបញ្ជាក់ប្រាប់ថា គេនឹងមិនព្រមទទួលស្គាល់ការតែងតាំងអាលីصلوات الله عليه والسلامទេ។ នេះគឺព្រះឆន្ទៈរបស់អល់ឡោះហ៍عز وجل ហើយជាព្រះឆន្ទៈរបស់អល់ឡោះហ៍عز وجلផងដែរដែល ពីមួយឆ្នាំទៅមួយឆ្នាំ ព្រះអង្គصلوات الله عليه والسلامបានបង្ហាញឲ្យឃើញសមត្ថភាពព្រះអង្គصلوات الله عليه والسلامយ៉ាងគ្រប់គ្រាន់ និងបានបង្ហាញឲ្យឃើញគុណសម្បត្តិព្រះអង្គصلوات الله عليه والسلامក្នុងការស្នងព្រះសាស្តា រីឯសាវកទាំងអស់ឯទៀតបានទទួលបរាជ័យក្នុងការបំពេញបេសកកម្មរបស់ខ្លួនយ៉ាងហោចណាស់មួយដង។

ការបដិសេធរបស់មុស្លីមភាគច្រើនបានឲ្យដឹងជាមុនហើយ ហើយព្រះសាស្តាﷺបានជ្រាបជាស្រេចហើយ។ តែព្រះបញ្ជាដ៏តឹងរ៉ឹងរបស់អល់ឡោះហ៍عز وجلបានធ្វើឲ្យព្រះសាស្តាﷺឈប់រួញរា ហើយបានកោះហៅមុស្លីមទាំងអស់មកប្រជុំមុននឹងបែកគ្នាបន្ទាប់ពីបានបំពេញពិធីធម្មយាត្រាហើយ។

ការណាត់ជួបគ្នាបានកំណត់នៅឯមាត់បឹងមួយ នៅកន្លែងមួយដែលហៅថាឃុម(خم)។ នៅទីនេះឯងដែល

ព្រះអង្គﷺបានធ្វើសុន្ទរកថាចំពោះមហាជន ដែលហៅថា "សុន្ទរកថាក៏ឌៀរ(غدير)" ។

សុន្ទរកថាមិនវែងប៉ុន្មានទេ ហើយអ្វីដែលច្បាស់នោះគឺប្រធានបទរបស់សុន្ទរកថានេះ គឺប្រកាសមរតករបស់ព្រះសាស្តាﷺផ្ទាល់មាត់តែម្តង ដែលមានសេចក្តីចុងក្រោយថាៈ



*អ្នកណាក៏ដោយដែលមានខ្ញុំﷺជាព្រះបរមគ្រូ អាលី صلوات الله عليه والسلام ជាព្រះបរមគ្រូរបស់អ្នកនោះ ។ អល់ឡោះហ៍عزّ وجلّ, អឺយ! សូមព្រះអង្គعزّ وجلّ,ជាមិត្តរបស់មិត្តគេ صلوات الله عليه والسلام សូមព្រះអង្គعزّ وجلّ,ជាសត្រូវរបស់សត្រូវគេ صلوات الله عليه والسلام ។ ខ្ញុំﷺបន្សល់ទុកឲ្យអស់លោកនូវបន្ទុកធ្ងន់ពីរ ។ ដរាបណាអស់លោកតោងវត្ថុទាំងពីរនេះជាប់ ដរាបនោះអស់លោកនឹងមិនវង្វេង*

*ឡើយ នោះគឺៈ គួរអាន ព្រះគម្ពីរអល់ឡោះហ៍ عزّ وجلّ, និងកូនចៅ(អាស្ហលុលបៃត៍)របស់ខ្ញុំ صلى الله عليه وآله وسلم ។ ដូច្នេះ ចូរអស់លោកប្រយ័តខ្លួន តើអស់លោកត្រូវធ្វើយ៉ាងណាខ្លះចំពោះពួកគេ عليهم السلام អត់ពីខ្ញុំ صلى الله عليه وآله وسلم ទៅនោះ ។*

ព្រមនឹងពេលដែលព្រះអង្គ صلى الله عليه وآله وسلم ថ្លែងសុន្ទរកថានេះ ព្រះអង្គ صلى الله عليه وآله وسلم បានចាប់ដៃអាលី صلوات الله عليه والسلام លើកឡើងលើដើម្បីឲ្យមនុស្សរាប់សិបពាន់នាក់ដែលមានវត្តមាននៅទីនោះបានឃើញយ៉ាងច្បាស់។

ពួកគេមួយចំនួនទើបតែបានឃើញអាលី صلوات الله عليه والسلام លើកដំបូង ចំណែកឯមួយចំនួនទៀតស្គាល់ព្រះអង្គ صلوات الله عليه والسلام ច្បាស់ណាស់ ហើយរំពឹងទុកថាព្រឹត្តិការណ៍នេះនឹងកើតឡើងពីព្រោះព្រះសាស្តា صلى الله عليه وآله وسلم បានលើកឡើងជាញឹកញយ។

សម្រង់សម្តីពាក់ព័ន្ធនឹងរឿងនេះមិនខ្វះទេ ឧទាហរណ៍ យ៉ាបៀរ អ៊ីបនូ អាប់ឌុលឡោះហ៍ សាវកភ័ក្តីម្នាក់របស់ព្រះសាស្តា صلى الله عليه وآله وسلم បានលើកឡើងថាៈ "*ពួកមុស្លីមស្គាល់ពួកពុតត្បុតអាស្រ័យលើកំហឹងដែលពួកគេមានចំពោះរូបអាលី صلوات الله عليه والسلام ។*"

ព្រះសាស្តា صلى الله عليه وآله وسلم មានព្រះវចនៈច្រើនលើកច្រើនគ្រាថាៈ "*អាលី صلوات الله عليه والسلام អើយ មានតែបុគ្គលពុតត្បុតទេដែលស្អប់អ្នក صلوات الله عليه والسلام ហើយមានតែបុគ្គលដែលមានសទ្ធាទេដែលស្រឡាញ់អ្នក صلوات الله عليه والسلام ។*"

ម្យ៉ាងវិញទៀត ចំណេះចេះដឹងរបស់អាលី صلوات الله عليه والسلام ត្រូវព្រះសាស្តា صلى الله عليه وآله وسلم សរសើរច្រើនលើកច្រើនគ្រា ហើយសាវកទាំងអស់របស់ព្រះអង្គ صلى الله عليه وآله وسلم ច្បាស់ជាបានឮព្រះអង្គ صلى الله عليه وآله وسلم មានព្រះវចនៈថាៈ

"*ខ្ញុំ صلى الله عليه وآله وسلم ជានគរនៃចំណេះចេះដឹង ចំណែកឯអាលី صلوات الله عليه والسلام ជាទ្វាររបស់នគរនោះ ។*"

ពេលព្រះសាស្តា صلى الله عليه وآله وسلم បានថ្លែងសុន្ទរកថាចប់ ពួកមុស្លីមបានគំនាប់អាលី صلوات الله عليه والسلام ដោយហៅព្រះនាមព្រះអង្គ صلى الله عليه وآله وسلم ដែលព្រះសាស្តា صلى الله عليه وآله وسلم បានដាក់ឲ្យនោះថា "អាមីរុល-មុមីនីន (أمير المؤمنين អគ្គមហាប្រមុខរបស់អ្នកមានសទ្ធា)"។

តាមផ្លូវច្បាប់ សំណុំរឿងស្នងព្រះសាស្តា صلى الله عليه وآله وسلم នោះបានចប់ស្រេចបាច់ហើយក្នុងថ្ងៃក៏ឌៀរនោះ។ តែមិនយូរប៉ុន្មាន ពួកមុស្លីមបានសម្តែងឲ្យឃើញនូវការបែរទៅរកការលុបមរតករបស់ព្រះសាស្តា صلى الله عليه وآله وسلم ចុងក្រោយចោលតែម្តង។

## ឧត្តរាធិការ

ព្រះទិវង្គតរបស់ព្រះសាស្តា صلى الله عليه وآله وسلم ធ្វើឲ្យមុស្លីមទូទៅភ្ញាក់ផ្អើលខ្លាំង។ ខណៈដែលក្រុមគ្រួសារព្រះសាស្តា صلى الله عليه وآله وسلم ព្រមទាំងអាលី صلوات الله عليه والسلام រវល់ធ្វើបុណ្យព្រះបរមសព សាវកមួយចំនួនរបស់ព្រះសាស្តា صلى الله عليه وآله وسلم និងមេកុលសម្ព័ន្ធមួយចំនួនតូចបានប្រជុំគ្នាក្នុងអង្គប្រជុំស្ងើរសម្ងាត់មួយនៅឯកន្លែងមួយដែលហៅថា "សាគីហ្វាស៊ុ"។

នៅក្នុងអង្គប្រជុំនេះ ពួកគេបានសម្រេចចិត្តមិនយកចិត្តទុកដាក់នឹងបណ្តាំ(មរតក)ព្រះសាស្តា صلى الله عليه وآله وسلم ទេ ហើយបានជ្រើសរើសអាប៊ូ-បាការ (ឬ អាប៊ូ-បាក់រ៍) ជាអ្នកស្នង(ជាខ៉លិហ្វ)បន្ទាប់ពីសហគមន៍អ៊ីស្លាមដ៏ក្មេងខ្ចីរិះនឹងបែកបាក់ព្រោះតែត្រូវការប្រយុទ្ធយ៉ាងស្វិតស្វាញគំរាមកំហែង។

ការជ្រើសរើសអាប៊ូ-បាការចោលអ៊ាលីصلوات الله عليه والسلامនោះ ជាការបើកផ្លូវឆ្ពោះទៅរកអំណាចឲ្យសំណាក់អ្នកប្រាជ្ញគូរ៉យ៉ស្វ៍និងពួកមេដឹកនាំនគរម៉ាឌីណាស្ទំមួយចំនួនក្នុងអនាគតកាល។

មែន ប្រសិនបើពួកគេព្រមធ្វើតាមព្រះបញ្ញាអល់ឡោះហ៍عز وجلនិងព្រះសាស្តាصلى الله عليه وآله وسلمព្រះអង្គعز وجلដោយឥតលំអៀង ហើយព្រមផ្ទេរអំណាចឲ្យទៅអ៊ាលីصلوات الله عليه والسلامនោះ សេចក្តីសង្ឃឹមថានឹងបានកាន់អំណាចក្នុងថ្ងៃណាមួយដោយការសម្រុះសម្រួលរវាងកុលសម្ព័ន្ធច្បាស់ជារលាយសាបសូន្យជាមិនខាន។

តែមិនយូរប៉ុន្មានភាគីមុស្លីមបានស្តាយក្រោយដែលបានរើសយកជម្រើសនេះ ជាពិសេសពេលការស្នងព្រះសាស្តាصلى الله عليه وآله وسلمនោះបានធ្លាក់ក្នុងដៃអ៊ុស្មាន ខ៏លិហ្វទីបី។



ទន្ទឹមនឹងពេលនេះ អាលី صلوات الله عليه والسلام បានដកខ្លួនពីឆាកនយោបាយដើម្បីរក្សាឯកភាពសហគមន៍អ៊ីស្លាមដោយយកចិត្តទុកដាក់ចំពោះតែការបង្ហាត់បង្រៀនសិក្ខាបទអ៊ីស្លាមនិងការផ្សព្វផ្សាយច្បាប់របស់អល់ឡោះហ៍ عزّ وجلّ ។

អាស្រ័យការខ្នះខ្នែងរបស់ព្រះអង្គ صلوات الله عليه والسلام ម៉ាស់យ៉ិដម៉ាឌីណាស់ក្លាយទៅជាវិទ្យាគារអ៊ីស្លាមពិតៗមួយ។ មុស្លីមគ្រប់រូបដែលចង់បានការចេះដឹងបានសំដៅមករកទីនេះពីទិសទាំងបួននៃដែនដីអ៊ីស្លាម។

លុះអំណាចបានធ្លាក់ទៅក្នុងកណ្តាប់ដៃអ៊ុស្ម៉ាន បុគ្គលរូបនេះមិនពន្យារពេលបើកដៃឲ្យបានី-អ៊ូម៉ៃយ៉ាស់(بنو أمية) នោះទេដែលជាក្រុមគ្រួសាររបស់អាប៊ូ-ស៊ុហ្វយ៉ាន និងជាសាច់ញាតិរបស់ខ្លួន។ ពួកគេបានសម្តែងនូវសេចក្តីត្រេកអរថ្ងៃតែងតាំងអ៊ុស្ម៉ានដោយថា៖ *"បានី-អ៊ូម៉ៃយ៉ាស់អើយ! ចូរទុកអំណាចឲ្យតែគ្នាឯង! សូមស្បថចំពោះអល់ឡោះហ៍ មិនមានឋាននរក មិនមានឋានសួគ៌ទេ មានតែការប្រយុទ្ធដើម្បីអំណាចទេ!"* តែត្រូវអ៊ុស្ម៉ានស្តីបន្ទោសឲ្យ ហើយក៏បានស្ងាត់មាត់ទៅ។

ទោះជាយ៉ាងណាក៏ដោយ អាប៊ូ-ស៊ុហ្វយ៉ានមិនមែនបុគ្គលពុតត្បុតតែម្នាក់ទេក្នុងចំណោមបានី-អ៊ូម៉ៃយ៉ាស់នោះ។ បុគ្គលគ្រោះថ្នាក់ជាងគេនៃកុលសម្ព័ន្ធនេះគឺ ម៉ារវ៉ាន អ៊ីបនូ អាល់-ហ្កាគីម(مروان بن الحكم)ដែលក្តាប់យកអំណាចទាំងអស់ដោយបានទៅជាលេខាផ្ទាល់ខ្លួនរបស់អ៊ុស្ម៉ាន។ កាលនោះឯងដែលគេបានឃើញមានការបែកបែរចេញពីមាគ៌ាត្រឹមត្រូវច្បាស់ក្រឡែតតែម្តង ហើយពួកមុស្លីមមិនអាចទ្រាំនៅដោយឥតអើពើបានទេ។

អាលី صلوات الله عليه والسلام មិនខានដាស់តឿនអ៊ុស្ម៉ានអំពីស្ថានភាពធ្ងន់ធ្ងរនេះទេ ហើយបានរំលឹកលោកថាកាលពីមុនម៉ារវ៉ានត្រូវព្រះសាស្តា ﷺ ដេញចេញពីម៉ាឌីណាស់។ តែការខិតខំប្រឹងប្រែងរបស់ព្រះអង្គ صلوات الله عليه والسلام ពុំមានប្រយោជន៍ទេ ស្ថានភាពកាន់តែដុនដាបទៅៗ បានឈានដល់ការបះបោរទូទៅ បន្ទាប់មកគេហដ្ឋានរបស់អ៊ុស្ម៉ានត្រូវឡោមព័ទ្ធ។

នៅក្នុងស្ថានភាពប្រកបដោយគ្រោះថ្នាក់នេះ អាលី صلوات الله عليه والسلام បានចាត់បញ្ជូនរាជបុត្រពីរអង្គ عليهم السلام របស់ព្រះអង្គ صلوات الله عليه والسلام អាល់-ហ្កាសាន់ صلوات الله عليه والسلام និងអាល់-ហ៊ុសៃន៍ صلوات الله عليه والسلام ដែលជានិមិត្តរូបនៃអាជ្ញាសាសនាអ៊ីស្លាម ទៅការពារអ៊ុស្ម៉ាន។

ជនបះបោរបានប្តេជ្ញាចិត្តបញ្ចប់ស្ថានភាពអាស្រូវនេះ គឺ៖ ពួកគេមិនអាចអត់ទ្រាំអំពើអយុត្តិធម៌ពីសំណាក់អភិបាលនគរ បានី-អ៊ូម៉ៃយ៉ាស់ បានទៀតទេ... ដោយបានឃើញសាវកភក្តីដូចជាអាប៊ូ-ស៊ារ(أبو ذر) អាំម៉ារ(عمار) ជាដើមត្រូវបណ្តេញចេញពីម៉ាឌីណាស់ ឬត្រូវវាយដោយរំពាត់ខ្សែតី ពួកគេអស់សង្ឃឹមលើរូបអ៊ុស្ម៉ាន ហើយពួកគេបានស្នើសូមឲ្យអ៊ុស្ម៉ានលាចេញពីតំណែង។ អ៊ុស្ម៉ានបានបដិសេធដោយបានថាលោកសុខចិត្តស្លាប់ជាជាងចោលតំណែង។

ក្នុងចន្លោះពេលនេះ បានី-អ៊ូម៉ៃយ៉ាស់រីករាយនឹងព្រឹត្តិការណ៍ដែលកើតឡើងនេះពីព្រោះមរណភាពរបស់អ៊ុស្ម៉ានអាចបើកដៃឲ្យពួកគេប្រើអំណាចផ្តាច់ការបានដើម្បីសងសឹកឲ្យលោក។

ដូច្នេះឯងដែលម៉ារវ៉ាននៅឯនគរម៉ាឌីណាស់និងមូអាវីយ៉ាស់ អភិបាលស្រុកស៊ីរី ដែលជាបងប្អូនលោកនោះ បានព្រមព្រៀងគ្នាមិនជួយជ្រោមជ្រែងអ៊ុស្ម៉ានទេ។ បុគ្គលទាំងពីររូបនេះបានរលាស់ដៃចោលអ៊ុស្ម៉ានទុកឲ្យលោកគ្មានពំនាក់អាស្រ័យ ហើយត្រូវស្លាប់ក្រោមការវាយដំរបស់ពួកបះបោរ។

ក្រោយពីអ៊ុស្មម៉ានបានស្លាប់ ភាគីមុស្លីមបានដឹងខ្លួនថាបានប្រព្រឹត្តខុសយ៉ាងធ្ងន់កាលពីម្ភៃឆ្នាំប្រាំមុននោះ គឺ៖ មិនអនុវត្តិតាមបណ្តាំរបស់ព្រះសាស្តា صلى الله عليه وآله وسلم ។ ព្រោះតែចង់រំដោះអ្វីដែលអាចរំដោះបាននោះ ពួកគេបានបែរមករកអ៊ុាលី صلوات الله عليه والسلام ចោមរោមព្រះអង្គ صلوات الله عليه والسلام ហើយបង្ខំឲ្យព្រះអង្គ صلوات الله عليه والسلام ឡើងកាន់អំណាច។

អ៊ីម៉ាំអ៊ុាលី صلوات الله عليه والسلام ព្រះអគ្គមហាប្រមុខស្របច្បាប់របស់មុស្លីម ដឹងថា បន្ទាប់ពីខ៊ុលិហ្វទាំងបីរូបនេះបានកាន់អំណាចអស់ម្ភៃប្រាំឆ្នាំហើយនោះ ព្រះអង្គ صلوات الله عليه والسلام ប្រហែលជាមិនអាចចាត់តាំងរដ្ឋាភិបាលអ៊ីស្លាមបានឲ្យដូចដែលអល់ឡោះហ៊្ វ عز وجل ដាក់មកនោះទេ។ ព្រះអង្គ صلوات الله عليه والسلام បានបដិសេធ។

ជនបះបោរនៅតែទទូចសូមព្រះអង្គ صلوات الله عليه والسلام ដល់ថ្នាក់គំរាមកំហែងព្រះអង្គ صلوات الله عليه والسلام ទៀតផង។ អ៊ុាលី صلوات الله عليه والسلام ឃើញថាសហគមន៍អ៊ីស្លាមកំពុងតែស្ថិតនៅក្នុងគ្រោះថ្នាក់។ ទីបំផុតព្រះអង្គ صلوات الله عليه والسلام បានបន្ទន់ទៅតាមការបង្ខិតបង្ខំរបស់ភាគីមុស្លីម ហើយព្រមកាន់អំណាចដោយដឹងច្បាស់ថាវាជាការលំបាកធំបំផុត។

# ៣-រដ្ឋាភិបាលរបស់ព្រះអគ្គមហាប្រមុខរបស់មុស្លីម

## អាលីប្រឈមនឹងពួកបះបោរ

ចាប់តាំងពីថ្ងៃដំបូង អ៊ីម៉ាំអាលី صلوات الله عليه والسلام បានប្រកាសនយោបាលរដ្ឋបាលព្រះអង្គ صلوات الله عليه والسلام ។ ទង់ស្មើភាពនិងយុត្តិធម៌ត្រូវបានបង្ហូតឡើងជាថ្មីបន្ទាប់ពីត្រូវគេជាន់ឈ្លីអស់រយៈពេលម្ភៃប្រាំឆ្នាំ។

ព្រះអង្គ صلوات الله عليه والسلام បានប្រកាសដោយឥតរួញរាថា ព្រះអង្គ صلوات الله عليه والسلام នឹងរៀបចំសណ្តាប់ធ្នាប់អល់ឡោះហ៍ عز وجل, និងប្រគល់សិទ្ធិដែលត្រូវគេបានប្លន់យកនោះឲ្យទៅម្ចាស់សិទ្ធិនោះវិញ។

ត្រូវរំលឹកឡើងវិញថា ចាប់តាំងពីព្រះសាស្តា ﷺ ចូលទិវង្គតទៅពួកមុស្លីមបានរស់នៅក្នុងប្រព័ន្ធវណ្ណៈសក្តិយស។ គេបានចាត់ឲ្យមានឋានានុក្រម(លំដាប់ឬរបៀប)មកលើពួកមុស្លីម។ អ្នកណាមានឋានន្តរសក្តិខ្ពស់អ្នកនោះនឹងបានទទួលតំណែងខ្ពស់ប្រចាំឆ្នាំក្នុងរដ្ឋាភិបាល។

ប្រព័ន្ធអយុត្តិធម៌នេះ ដែលបានប្រព្រឹត្តទៅអស់រយៈពេលម្ភៃប្រាំឆ្នាំ ជាដើមហេតុនៃអំពើពុករលួយក្នុងចំណោមសាវកភាគច្រើនរបស់ព្រះសាស្តា ﷺ ។ ពួកនេះបានដឹងខ្លួនថាពួកគេជាចំណុចតម្រង់ ពេលអាលី صلوات الله عليه والسلام កាន់អំណាច ក៏បានឃើញថាផលប្រយោជន៍របស់ខ្លួនត្រូវគំរាមកំហែង។

ពួកអ្នកមានទ្រព្យសម្បត្តិជាងគេបានរួបរួមគ្នាជារណសិរ្ស ដើម្បីការពារផលប្រយោជន៍អនាគតរបស់ពួកគេ។

អតីតសាវករបស់ព្រះសាស្តា ﷺ មួយចំនួនបានជ្រើសយកការសម្លុត ហើយបានមកជួបព្រះអគ្គមហាប្រមុខរបស់អ្នកមានសទ្ធា ដើម្បីសូមឲ្យព្រះអង្គ صلوات الله عليه والسلام តែងតាំងពួកគេជាអភិបាលស្រុកមុស្លីមពីរដែលសម្បូរជាងគេ គឺៈ ស្រុកបាស្វរ៉ោះត៍(البصرة)និងស្រុកគូហ្វាស់(الكوفة)។

អ៊ីម៉ាំ صلوات الله عليه والسلام បានបដិសេធដាច់ខាត។ ខកចិត្ត ពួកអតីតសាវកទាំងនេះបានរៀបចំសង្គ្រាមប្រឆាំងព្រះអគ្គមហាប្រមុខរបស់អ្នកមានសទ្ធា ដោយយកលេសថាព្រះអង្គ صلوات الله عليه والسلام មិនសូវខ្នះខ្នែងខិតខំតាមចាប់ខ្លួនឃាតកររបស់អ៊ុស្មានទេ។

ពួកគេបានបញ្ចុះបញ្ចូលអគ្គមហេសីរបស់ព្រះសាស្តា ﷺ មួយរូបឲ្យគាំទ្រពួកគេ ហើយបាននាំព្រះនាងទៅតាមពួកគេលើខ្នងអូដ្ឋ។ នេះគឺសមរភូមិអូដ្ឋ(معركة الجمل)ដែលបានកើតឡើងនៅឯបាស្វរ៉ោះត៍។

សមរភូមិបង្ហូរឈាមនេះបានហុចជ័យជំនះដ៏ត្រចះត្រចង់ ឲ្យទៅព្រះអគ្គមហាប្រមុខ صلوات الله عليه والسلام របស់អ្នកមានសទ្ធា។ ព្រះអង្គ صلوات الله عليه والسلام បានចាប់ផ្តើមត្រៀមខ្លួនប្រយុទ្ធក្នុងសមរភូមិធំមួយទៀតទល់នឹងសត្រូវធំរបស់ព្រះអង្គ صلوات الله عليه والسلام គឺមូអាវីយ៉ាស្ អភិបាលបះបោររបស់ស្រុកដាម៉ាស់។

ពួកពុតត្បុតទាំងអស់ ដែលមិនបានរងគ្រោះភ័យក្នុងសមរភូមិអូដ្ឋបានប្រមូលផ្តុំគ្នាជុំវិញមូអាវីយ៉ាស់ ដោយមានម៉ារវ៉ានជាមេដឹកនាំពួកគេ។

មូអាវីយ៉ាស់ជាមនុស្សមានល្បិចច្រើន ចេះបង្វិលខួរក្បាលមនុស្សមិនសូវឆ្លាតវៃ ហើយចេះសាបព្រោះ

សេចក្តីសង្ស័យក្នុងអារម្មណ៍។



កាលលោកបានទទួលបរាជ័យក្នុងសមរភូមិស៊ីហ្វហ្វីន(صفين) លោកបានប្រើកលល្បិចមួយ។ លោកបានបញ្ជាឲ្យយកគម្ពីរអានដាក់លើចុងលំពែងហើយលើកឡើងលើ ហើយឲ្យស្រែកសូមឲ្យយកគម្ពីរអានជាអាជ្ញាកណ្តាល។

អ៊ីម៉ាំអាលី صلوات الله عليه والسلام យល់ល្បិចរបស់មូអាវីយ៉ាស់ច្បាស់ណាស់។ ព្រះអង្គ صلوات الله عليه والسلام បានបញ្ជាឲ្យបន្តការប្រយុទ្ធដោយកុំយកចិត្តទុកដាក់នឹងកលល្បិចរបស់សត្រូវ។ តែកងទ័ពមួយប៉ែកធំមិនព្រមស្តាប់បញ្ជាព្រះអង្គ صلوات الله عليه والسلام ទេ

ហើយបានបង្ខំឲ្យព្រះអង្គصلوات الله عليه والسلامបញ្ឈប់ការប្រយុទ្ធនិងព្រមទទួលស្គាល់អាជ្ញាកណ្តាលនោះ។

ក្រោយពីនោះមក បុគ្គលទាំងនេះដែលបានបង្ខំព្រះអគ្គមហាប្រមុខصلوات الله عليه والسلامរបស់ពួកគេឲ្យបញ្ឈប់ការប្រយុទ្ធនោះបានដឹងថានេះគ្រាន់តែជាល្បិចកលរបស់ជនកំហូចប៉ុណ្ណោះ ហើយបានដឹងថាមូអាវីយ៉ាស់គ្រាន់តែចង់ចៀសវាងបរាជ័យទាំងស្រុងរបស់ខ្លួនប៉ុណ្ណោះទេ។

ព្រោះតែងងឹតវិងស៊ីងដោយសារកំហឹង និងងងឹតល្ងង់ ពួកគេបានប្រកាសសង្គ្រាមចំពោះយុទ្ធការីទាំងអស់ពោលគឺ ពួកគេបានប្រកាសសង្គ្រាមចំពោះអ៊ីម៉ាំអាលីصلوات الله عليه والسلامដែលសមស្របតាមច្បាប់ និងចំពោះមូអាវីយ៉ាស់បុគ្គលបះបោរនោះដែរ ដែលជាសត្រូវរបស់ព្រះអង្គصلوات الله عليه والسلام។

គេហៅចលនាប្រទូសមិនសមហេតុផលនិងខ្វះការរិះគិតនេះថា ចលនាបែកចេញ(خارجي ឬ الخوارج)។ ពួកគេត្រូវប្រល័យនៅក្នុងសមរភូមិណាស់រ៉ាវ៉ាន់(معركة النهروان) ដោយព្រះអគ្គមហាប្រមុខصلوات الله عليه والسلامរបស់អ្នកមានសទ្ធាជ្រះថ្លា ក្រោយពីពួកគេភាគច្រើនបានភ្ញាក់រលឹកដឹងកំហុស។

ពួកខ៉ាវ៉ារីច្(ពួកបែកចេញ)បីនាក់ ក្នុងចំណោមពួកខ៉ាវ៉ារីច្ររួចជីវិតពីសមរភូមិណាស់រ៉ាវ៉ាន់ បានប្រជុំគ្នាស្ងាត់ៗហើយបានសម្រេចចិត្តសម្លាប់អស់បុគ្គលណាដែលពួកគេចាត់ទុកថា ជាអ្នកទទួលខុសត្រូវចំពោះសង្គ្រាមស៊ីវិលគឺ៖ អុំរ៉ូ អ៊ីបនូ អាល់-អាស្វ័រ(عمرو بن العاص) អភិបាលស្រុកអេស៊ីបក្នុងនាមមូអាវីយ៉ាស់ អភិបាលបះបោរនៃស្រុកដ្ងាម៉ាស់ និងអាលីصلوات الله عليه والسلام ព្រះអគ្គមហាប្រមុខصلوات الله عليه والسلامរបស់អ្នកមានសទ្ធាជ្រះថ្លា ខ៉លិហ្វស្របច្បាប់។

បុគ្គលអវិជ្ជាទាំងបីរូបនេះបានសម្រេចយកថ្ងៃទី ១៩ ខែរ៉ម៉ាដ្ធន ឆ្នាំទី ៤០ សករាជហ៊ីច្រ៉ោះត៍ ដើម្បីប្រតិបត្តិតាមគម្រោងការពួកគេ។ អាប់ឌុរ-រ៉ោះហ្ម៉ាន អ៊ីបនូ មូលយ៉ាំ(عبدالرحمن بن ملجم) បុគ្គលដែលទទួលភារកិច្ចធ្វើឃាតអ៊ីម៉ាំអាលីصلوات الله عليه والسلامមានល្បិចជាងបុគ្គលពីរនាក់ទៀត។ គាត់បានលាបថ្នាំពិសលើដាវគាត់ហើយទៅកាន់គូហ្វាស់។

## ទុក្ករកម្មរបស់អាលី صلوات الله عليه والسلام

នៅពេលដែលព្រះអគ្គមហាប្រមុខصلوات الله عليه والسلامរបស់អ្នកមានសទ្ធាជ្រះថ្លា កំពុងតែបំពេញស្វ៉ឡាត់ពេលមុនថ្ងៃរះឃាតករអប្រិយបានចូលមកក្នុងម៉ាស់យ៉ិដ្ធ។ ខណៈដែលព្រះអង្គصلوات الله عليه والسلامងើបពីក្រាបប្រណិប័តន៍វិញ ដាវពិសរបស់អ៊ីបនូ មូលយ៉ាំបានកាប់លើថ្ងាសព្រះអង្គصلوات الله عليه والسلام។

អាលីصلوات الله عليه والسلامបានស្រែកថា៖ "*សូមស្បថចំពោះព្រះجلّ علىរបស់កាក់បាស់ ខ្ញុំصلوات الله عليه والسلامបានសម្រេចហើយ!*"

ខណៈនោះ គេបានឮពេញនគរគូហ្វាស់សម្រែកនេះ គឺ៖ "*សសរកន្ទោងនៃទិសដៅល្អបានរលំហើយ ។ សូមស្បថចំពោះឪកجلّ علىៈ, បុគ្គលដែលមានសទ្ធាជ្រះថ្លាបំផុតក្នុងចំណោមបុគ្គលដែលមានសទ្ធាជ្រះថ្លាត្រូវគេធ្វើឃាតហើយ! ព្រះអង្គصلوات الله عليه والسلامត្រូវបុគ្គលអប្រិយបំផុតធ្វើឃាត!*"

ឈាមព្រះអង្គصلوات الله عليه والسلامបានហូរមកលើមិះហ្ម៉ាប់(مِحْراب) បណ្តាលឲ្យមិះហ្ម៉ាប់ក្រហមឆ្អៅ... ឃាតករព្យាយាមរត់គេចខ្លួនតែត្រូវអ្នកមានសទ្ធាពីរបីនាក់ចាប់បាន ហើយត្រូវនាំខ្លួនទៅឯផ្ទះអ៊ីម៉ាំអាលីصلوات الله عليه والسلام។ ព្រះអង្គصلوات الله عليه والسلامបាននិយាយជាមួយឃាតករនោះថា៖ "*តើខ្ញុំصلوات الله عليه والسلامមិនបានធ្វើល្អលើរូបអ្នកទេឬ?*" អ៊ីបនូ មូលយ៉ាំបានតបថា៖ "*បានធ្វើមែន ។*"



គេប៉ុនប៉ងសងសឹកឃាតករ តែព្រះអគ្គមហាប្រមុខ صلوات الله عليه والسلام របស់អ្នកមានសទ្ធាបានហាម ហើយបានប្រាប់ឲ្យអាល់-ហ្សាសាន់ صلوات الله عليه والسلام ព្រះរាជបុត្រ صلوات الله عليه والسلام ច្បងរបស់ព្រះអង្គ صلوات الله عليه والسلام ប្រព្រឹត្តល្អលើឃាតករដរាបណាបុគ្គលនេះនៅមានជីវិត ហើយឲ្យប្រើច្បាប់អ៊ីស្លាមចំពោះបុគ្គលនេះពេលព្រះអង្គ صلوات الله عليه والسلام សោយទិវង្គត។

ពីរថ្ងៃកន្លងមក ថ្ងៃទី ២១ ខែរ៉ម៉ាដូន អ៊ាលី صلوات الله عليه والسلام ព្រះអគ្គមហាប្រមុខ صلوات الله عليه والسلام របស់អ្នកមានសទ្ធាបានចាកលោកទៅរកព្រះម្ចាស់ عز وجل ព្រះអង្គ صلوات الله عليه والسلام ។ វិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ صلوات الله عليه والسلام បានជួបជុំព្រះរាជវង្សានុវង្សរបស់ព្រះអង្គ صلوات الله عليه والسلام ។ ទុក្ខរកម្មរបស់ព្រះអគ្គមហាប្រមុខ صلوات الله عليه والسلام របស់អ្នកមានសទ្ធាបានកើតឡើងពេលព្រះអង្គ صلوات الله عليه والسلام

មានព្រះជន្មស្មើព្រះជន្មព្រះសាស្ដា ﷺ កាលព្រះអង្គ ﷺ បានសោយទិវង្គត គឺ ៦៣ វស្សា។



ការបញ្ចុះព្រះរាជសពព្រះអង្គ صلوات الله عليه والسلام បានប្រព្រឹត្តទៅដោយមិនឲ្យគេដឹងទេ។ ព្រោះតែខ្លាចពួកសត្រូវព្រះអង្គ صلوات الله عليه والسلام ប្រមាថផ្នូរព្រះអង្គ صلوات الله عليه والسلام គេបានលាក់មិនឲ្យអ្នកណាស្គាល់ផ្នូរព្រះអង្គ صلوات الله عليه والسلام នោះទេអស់រយៈពេលមួយសតវត្ស

# សម្រង់សីលធម៌ត្រចះត្រចង់របស់អ៊ាលី صلوات الله عليه والسلام ក្នុងទំព័រប្រវត្តិសាស្រ្ត

១/ នគរគូហ្វាស់ អាស្រ័យព្រះវត្តមានរបស់អ៊ាលីصلوات الله عليه والسلام បានក្លាយទៅជារាជធានីនៃចំណេះវិជ្ជានិងនយោបាយរបស់លោកអ៊ីស្លាម។ ព្រះរស្មីចែងចាំងសាយសុសចេញពីនគរនេះទៅកាន់គ្រប់តំបន់ដែនដី។

វត្តមានរបស់ព្រះអគ្គមហាប្រមុខصلوات الله عليه والسلامរបស់អ្នកមានសទ្ធា មិនត្រឹមតែជាវត្តមាននយោបាយនិងវិជ្ជាសាស្រ្តប៉ុណ្ណោះទេ។ ផ្ទុយទៅវិញ អ៊ាលីصلوات الله عليه والسلامផ្តល់ឲ្យបណ្តាអ្នកដែលទើបនឹងបានចូលជ្រកក្រោមសាសនាអ៊ីស្លាមនូវការយល់ឃើញថ្មីៗ។

ពិតណាស់ មុស្លីមទាំងនេះ ដែលបានមកកាន់ទីនេះពីទិសទាំងបួនដើម្បីក្រេបយកនូវចំណេះព្រះធម៌ អាចឃើញមាននៅទីនេះនូវសីលធម៌ដែលចម្លងត្រឹមត្រូវតាមសីលធម៌របស់ព្រះសាស្តាصلوات الله عليه والسلام គឺសីលធម៌ដ៏ឧត្តុង្គឧត្តមរុងរឿងដែលជាគំរូអចិន្ត្រៃយ៍សម្រាប់បុគ្គលដែលស្វែងរកភាពឥតខ្ចោះ និងសម្រាប់បុគ្គលដែលប៉ុនប៉ងចង់បានសុក្រឹតភាព។

ថ្ងៃមួយ ផ្លូវទៅកាន់នគរគូហ្វាស់បានដឹកនាំបុគ្គលពីរនាក់ដែលមិនធ្លាប់ស្គាល់គ្នាសោះឲ្យបានស្គាល់គ្នា។ ម្នាក់គឺអ៊ាលីصلوات الله عليه والسلام ឯម្នាក់ទៀតគឺបុរសអ្នកកាន់សាសនាគ្រិស្តដែលរស់នៅក្បែរៗនគរគូហ្វាស់។

លុះបានទៅដល់ផ្លូវត្រឡែងកែង បុរសទាំងពីរត្រូវបែកគ្នា តែអ៊ាលីصلوات الله عليه والسلامបានជូនដំណើរបុរសកាន់សាសនាគ្រិស្តទៅកាន់ភូមិគាត់។ បុរសរូបនេះដឹងថាគោលដៅរបស់អ៊ាលីصلوات الله عليه والسلامគឺគូហ្វាស់ ក៏បានសួរព្រះអង្គصلوات الله عليه والسلامថា៖ "គោលដៅរបស់លោកគឺគូហ្វាស់មែនទេ?" អ៊ាលីصلوات الله عليه والسلامបានឆ្លើយគាត់ថា៖ "មែន តែខ្ញុំចង់ជូនដំណើរលោកក្នុងនាមមិត្តភាពរួមដំណើររបស់យើងទាំងពីរ។ ការរាប់រកគ្នាពេលធ្វើដំណើរមានសិទ្ធិរបស់វា។ ខ្ញុំចូលចិត្តគោរពសិទ្ធិទាំងអស់។"

ការសមហេតុសមផលនិងសីលធម៌នេះធ្វើឲ្យបុរសគ្រិស្តសាសនិកស្ងប់ស្ងែងអនេក។ គាត់នឹកក្នុងចិត្តថាមានតែសាសនារបស់ព្រះពិតទេដែលប្រកបដោយគុណធម៌អស្ចារ្យនេះ។ ក្រោយមកគាត់បានប្តូរសាសនា មកកាន់សាសនាអ៊ីស្លាមវិញ។

គាត់បានភ្ញាក់ផ្អើលខ្លាំង ពេលបានដឹងថាមិត្តរួមដំណើររបស់គាត់នោះមិនមែនអ្នកណាក្រៅពីព្រះអគ្គមហាប្រមុខصلوات الله عليه والسلامរបស់អ្នកមានសទ្ធាទេ ជាខ៍លិហ្វរបស់មុស្លីមទាំងអស់និងជាអភិបាលរបស់ដែនដីធំធេងទាំងអស់របស់អ៊ីស្លាម។

២/ ការធ្វើសឹកទាំងអស់របស់អ៊ាលីصلوات الله عليه والسلامជាគំរូត្រចះត្រចង់ប្រកបដោយសីលធម៌សម្រាប់យើង។ ព្រះអង្គصلوات الله عليه والسلامមិនសម្លាប់ជនរងរបួសឡើយ មិនបង្អត់ទឹកឡើយ ហើយមិនប្រដេញតាមសត្រូវបាក់ទ័ពឡើយ។ ព្រះអង្គصلوات الله عليه والسلامមិនប្រើអាវុធសម្រេកទឹកជាដាច់ខាត រីឯសត្រូវរបស់ព្រះអង្គصلوات الله عليه والسلامវិញតែងតែប្រើវិធីនេះក្នុងគ្រប់សមរភូមិរបស់ពួកគេ។

ដើម្បីបំភ្លឺការពិតនេះ យើងលើកឡើងតែគំរូមួយទេ។ សៀវភៅប្រវត្តិសាស្រ្តសម្បូរនូវភ័ស្តុតាងច្រើនទៀត។

នៅឯសមរភូមិស៊ីហ្វហ៊្វីន(صفين) មុនចាប់ផ្តើមប្រយុទ្ធ ទ័ពរបស់មូអ៊ាវីយ៉ាស់បានមកដល់លានប្រយុទ្ធមុនគេដែលនៅក្បែរមាត់ស្ទឹងអាល់-ហ្វ៊ូរ៉ាត(الفرات-Euphrate)។ ទ័ពនេះបានឆ្លៀតយកឱកាសពាំងផ្លូវរវាងទឹកនិងទ័ពរបស់

អ៊ីម៉ាំអ៊ាលី صلوات الله عليه والسلام ហាមឃាត់មិនឲ្យអ្នកភ័ក្តីចំពោះអ៊ាលី صلوات الله عليه والسلام អាចបំបាត់ការស្រេកទឹកបានទេ។

អ៊ីម៉ាំអ៊ាលី صلوات الله عليه والسلام បានបញ្ជាឲ្យវាយដណ្តើមយកទឹក។ បន្ទាប់ពីបានប្រយុទ្ធយ៉ាងឆាប់ ពួកបោះបោរបានដកថយ ឯពួកភ័ក្តីចំពោះអ៊ាលី صلوات الله عليه والسلام បានកាន់កាប់ទីតាំងទាំងអស់ដែលក្តាប់លើស្ទឹងអាល់-ហ្វ៊ូរ៉ត។ ពួកគេចង់ប្រើអាវុធសម្រេកទឹកដូចគូប្រយុទ្ធរបស់ពួកគេដែរ។ តែបញ្ញារបស់ព្រះអគ្គមហាប្រមុខ صلوات الله عليه والسلام របស់អ្នកមានសទ្ធាតឹងរ៉ឹងណាស់ គឺ៖ ចាំបាច់ត្រូវតែដកថយពីមាត់ស្ទឹងភ្លាម ហាមប្រើអាវុធសម្រេកទឹកព្រោះ យោលតាមសីលធម៌របស់អ៊ីម៉ាំអ៊ាលី صلوات الله عليه والسلام មិនអាចប្រើគ្រប់មធ្យោបាយបានឡើយដើម្បីដណ្តើមយកជ័យជំនះនោះ។ គេមិនអាចធ្វើឲ្យអល់ឡោះហ៊ូ عز وجل សព្វព្រះហឫទ័យបានឡើយ ដោយជ្រើសយកមធ្យោបាយមិនត្រឹមត្រូវបណ្តាលឲ្យព្រះអង្គ عز وجل ទ្រង់ព្រះពិរោធនោះ។

អ៊ីម៉ាំអ៊ាលី صلوات الله عليه والسلام មានព្រះវចនៈថា៖ "មិនខ្វះទេមេរៀន ខ្វះតែអ្នកមើលឃើញលទ្ធផលចុងក្រោយរបស់មេរៀន។"

៣/ សេចក្តីរាបទាប មិនលើកកំពស់ខ្លួនជាគុណសម្បត្តិមួយរបស់អ៊ីម៉ាំអ៊ាលី صلوات الله عليه والسلام ដែលគេស្គាល់ជាងគេ។ អាការក្រៅរបស់ព្រះអង្គ صلوات الله عليه والسلام មិនខុសពីមនុស្សដទៃទេ ហើយចរិយាមារយាទរបស់ព្រះអង្គ صلوات الله عليه والسلام ចំពោះមហាជននោះសាមញ្ញណាស់ ដល់ថ្នាក់ពួកគេមិនអាចកត់សំគាល់បានឡើយថាព្រះអង្គ صلوات الله عليه والسلام ជាអ្នកណានោះទេ។

យើងសូមលើកយកមកនូវគំរូមួយដើម្បីបំភ្លឺ គឺរឿងស្វាមីភរិយាមួយគូដែលបានឈ្លោះប្រកែកគ្នា។

ស្វាមីបានបណ្តេញភរិយាខ្លួនចេញពីផ្ទះទាំងកណ្តាលថ្ងៃត្រង់ដែលកំពុងក្តៅខ្លាំង។ ភរិយាអកុសលមិនដឹងពឹងពាក់អ្នកណាក្រៅពីអ៊ីម៉ាំអ៊ាលី صلوات الله عليه والسلام ទេ។ លុះបានជ្រាបរឿងរ៉ាវហើយ ព្រះអង្គ صلوات الله عليه والسلام បាននាំគាត់ទៅផ្ទះវិញដើម្បីជួយផ្សះផ្សា។

ព្រះអគ្គមហាប្រមុខ صلوات الله عليه والسلام បានគោះទ្វារ។ បុរសជាស្វាមីបានបើកទ្វារ។ លុះបានឃើញបុរសប្លែកមុខដែលខ្លួនមិនធ្លាប់ស្គាល់មកលូកដៃក្នុងរឿងផ្ទាល់ខ្លួនរបស់គេនោះ បុរសរូបនេះបានឆ្លើយតបការដាស់តឿនរបស់អ៊ីម៉ាំអ៊ាលី صلوات الله عليه والسلام វិញដោយជេរប្រទេចព្រះអង្គ صلوات الله عليه والسلام ហើយបានស្រែកគំរាមកំហែងដាក់មុខភរិយាខ្លួនដោយការធ្វើទណ្ឌកម្មគ្រប់បែបយ៉ាងព្រោះតែនាងហ៊ាននាំបុរសប្លែកមុខមក។

ស្របនឹងពេលនេះ អ្នកខ្លះដែលស្គាល់អ៊ីម៉ាំអ៊ាលី صلوات الله عليه والسلام បានមកគោរពព្រះអង្គ عليه السلام ថា៖ "សូមសិរីសួស្តីកើតមានលើព្រះអង្គ صلوات الله عليه والسلام ឱព្រះអគ្គមហាប្រមុខ صلوات الله عليه والسلام របស់អ្នកមានសទ្ធាអើយ!" បុរសជាស្វាមីស្រឡាំងកាំង បានស្ទុះមកថើបដៃអ៊ីម៉ាំអ៊ាលី صلوات الله عليه والسلام និងសូមខមាទោសព្រះអង្គ صلوات الله عليه والسلام ដោយសន្យាថានឹងមិនប្រព្រឹត្តបែបនេះទៀតទេ។ អ៊ីម៉ាំ صلوات الله عليه والسلام បានផ្តល់ដំបូន្មានដ៏មានតម្លៃដល់គូស្វាមីភរិយាក្មេងនេះ ដំបូន្មានដែលធានានូវជីវិតប្រកបដោយសុភមង្គលនិងគ្មានបញ្ហា។

# ៤-តួយ៉ាងសុក្រឹតរបស់យុត្តិធម៌

## ១-អ៊ីម៉ាំរបស់ជនក្រីក្រ

ទោះជាអ៊ីម៉ាំអាលី صلوات الله عليه والسلام រវល់នឹងបញ្ហាធំៗក៏ដោយ ព្រះអង្គ صلوات الله عليه والسلام តែងតែយកចិត្តទុកដាក់នឹងសេចក្តីត្រូវការនិងការត្អូញត្អែររបស់ប្រជារាស្ត្រជានិច្ច។

ព្រះអង្គ صلوات الله عليه والسلام កាន់ក្តាប់ក្រសួងហិរញ្ញវត្ថុ(بيت المال)ដោយព្រះអង្គ صلوات الله عليه والسلام ឯង។ ព្រះអង្គ صلوات الله عليه والسلام មិនបង្អត់អ្នកណាម្នាក់ពីចំនួនថវិកាដែលខ្លួនត្រូវបាននោះទេ ទោះជាព្រះអង្គ صلوات الله عليه والسلام ដឹងច្បាស់ថាអ្នកនោះគុំគួនព្រះអង្គ صلوات الله عليه والسلام ក៏ដោយ ឬអ្នកនោះយកប្រាក់នេះទៅជួយពង្រឹងកម្លាំងសត្រូវរបស់ព្រះអង្គ صلوات الله عليه والسلام ក៏ដោយ។

ម្យ៉ាងវិញទៀត សាវកភក្តីរបស់ព្រះអង្គ صلوات الله عليه والسلام និងសាច់ញាតិរបស់ព្រះអង្គ صلوات الله عليه والسلام មិនបានទទួលឯកសិទ្ធិលើសជនសាមញ្ញទេ។ ចំណែកថវិការបស់ពួកគេសមស្របនឹងច្បាប់សាធារណៈដែលអនុម័តទៅលើមុស្លីមទាំងអស់នោះដែរ។ ពោលឲ្យខ្លីគឺ ប្រពន្ធវណ្ណៈ(ការរើសអើងវណ្ណៈ)និងឯកសិទ្ធិដែលខលិហ្វបីរូបមុនៗបានរក្សាទុកនោះនឹងត្រូវលុបចោលដោយអ៊ីម៉ាំអាលី صلوات الله عليه والسلام ។

អ៊ីម៉ាំអាលី صلوات الله عليه والسلام ជាសម្ពន្ធមិត្តរបស់មហាជន ព្រះអង្គ صلوات الله عليه والسلام ស្នើសូមឲ្យមន្ត្រីទាំងអស់របស់ព្រះអង្គ صلوات الله عليه والسلام ធ្វើដូចនេះដែរ។ រាល់គ្រាដែលមន្ត្រីរូបណាមួយ ក្នុងចំណោមមន្ត្រីទាំងនេះ លំអៀងចេញពីមាគ៌ានេះពិតមែន ព្រះអង្គ صلوات الله عليه والسلام មិនរួញរាដេញមន្ត្រីរូបនោះចោលឡើយ។

ថ្ងៃមួយ ស្ត្រីម្នាក់ឈ្មោះសៅដ្ហាស៊ុ(سودة)បានមកឯផ្ទះព្រះអគ្គមហាប្រមុខរបស់អ្នកមានសទ្ធា ខណៈដែលព្រះអង្គ صلوات الله عليه والسلام កំពុងធ្វើសក្ការបូជាអល់ឡោះហ៊្ល عزّ وجلّ ដើម្បីប្តឹងពីមន្ត្រីហូតពន្ធពីរបីនាក់។ ដោយដឹងថាមានគេមកក្រោយខ្នងព្រះអង្គ صلوات الله عليه والسلام អ៊ីម៉ាំ صلوات الله عليه والسلام បានបង្ហើយការបំពេញនមស្ការព្រះអង្គ صلوات الله عليه والسلام ហើយបានបែរមករកនារីនោះភ្លាមដោយសួរយ៉ាងរាក់ទាក់ថា៖ "តើអ្នកមានធុរៈអ្វី?" ស្ត្រីនោះបានទូលដោយយំយែកថា៖ "ខ្ញុំម្ចាស់មកប្តឹងពីអ្នកហូតពន្ធរបស់ព្រះអង្គ صلوات الله عليه والسلام ។" រឿងនេះធ្វើឲ្យអ៊ីម៉ាំ صلوات الله عليه والسلام រំភើបអារម្មណ៍ណាស់ ព្រះអង្គ صلوات الله عليه والسلام យំ លើកដៃឡើងហើយបានទូលថា៖ "ព្រះម្ចាស់ عزّ وجلّ ទូលព្រះបង្គំជាខ្ញុំអើយ! ព្រះអង្គ عزّ وجلّ ទ្រង់ញាណច្បាស់ណាស់ថាទូលព្រះបង្គំជាខ្ញុំមិនបានបញ្ជាឲ្យប្រព្រឹត្តដោយអយុត្តិធម៌ចំពោះបាវបម្រើទាំងឡាយរបស់ព្រះអង្គ عزّ وجلّ ទេ!" ដោយបានដឹងថាសម្តីរបស់ស្ត្រីរូបនោះជាការពិតមែន ព្រះអង្គ صلوات الله عليه والسلام បានចេញបញ្ជាជាលាយលក្ខណ៍អក្សរឲ្យដកតំណែងមន្ត្រីហូតពន្ធដែលត្រូវចោទប្រកាន់នោះ ហើយបានចាត់ឲ្យស្ត្រីដដែលរូបនេះយកសំបុត្រនេះទៅឲ្យមន្ត្រីអ្នកហូតពន្ធរូបនោះ។ សៅដ្ហាស៊ុបានត្រឡប់មកផ្ទះវិញដោយសមបំណង។

ថ្ងៃមួយ ដំណឹងពីនគរបាស្រ៉ោះត៊ុ(البصرة)បានធ្វើសេចក្តីរាយកាណ៍ថាអភិបាលស្រុកនេះ ដែលមានឈ្មោះថា អ៊ុស្មម៉ាន អ៊ីបនូ ហ៊ានិហ្វ បានយល់ព្រមទទួលការអញ្ជើញចូលរួមក្នុងការបរិភោគលៀងធុរកិច្ច។ អ៊ីម៉ាំ صلوات الله عليه والسلام បានផ្ញើសារវែងមួយមកឲ្យគាត់ កាត់ទោសការប្រព្រឹត្តរបស់គាត់ ហើយបានដាស់តឿនគាត់ឲ្យប្រុងប្រយ័តការ

អញ្ជើញប្រភេទនេះ។ ព្រះអង្គ صلوات الله عليه والسلام បានប្រាប់ហើយប្រាប់ទៀតថាពួកអ្នកមានទ្រព្យដែលចាត់ចែងពិធីបែបនេះឡើងមិនមែនចង់បង្កើតមូលនិធិជួយទ្រទ្រង់ជនក្រីក្រទេ តែនេះជាសំណូកមួយប្រភេទនិងជាការសូកប៉ាន់អភិបាល និងជាការស្វែងរកអាជ្ញានិងអំណាចនៅក្នុងស្រុក។

ការពិត លិខិតនេះសម្បូរដោយវិន័យសីលធម៌និងវិន័យនយោបាយ ហើយសមជាគំរូយ៉ាងសម្រាប់អំណាចអ៊ីស្លាម។



ពេលសង្ខេប អ៊ីម៉ាំ صلوات الله عليه والسلام បាននិយាយជាមួយអ៊ីបនូ ហ៊ានិហ្វ អភិបាលស្រុករបស់ព្រះអង្គ صلوات الله عليه والسلام ថា៖ "*ខ្ញុំមិននឹកស្មានថាលោកព្រមទទួលការអញ្ជើញរបស់ពួកដែលមិនអើពើនឹងជនក្រីក្រ ហើយបែរជាអើពើជនមានទ្រព្យវិញនោះទេ ។ មិនមែនទេឬ ម្នាក់ៗយកតម្រាប់តាមអ៊ីម៉ាំនិងមគ្គទេសក៍របស់ខ្លួន ហើយបំភ្លឺខ្លួនឯងអាស្រ័យលើពន្លឺនិងចំណេះចេះដឹងរបស់អ៊ីម៉ាំនិងមគ្គទេសក៍នោះ! មិនមែនទេឬ អ៊ីម៉ាំរបស់អស់លោកពេញចិត្តនឹងការស្លៀកពាក់រហែករយ៉ែ ពេញចិត្តនឹងបាយ(ក្រៀមក្រោះ)របស់ខ្លួន!*"

ថ្ងៃមួយ គេបានសួរសាវកម្នាក់របស់អ៊ីម៉ាំអាលី صلوات الله عليه والسلام ឈ្មោះអាឌី អ៊ីបនូ ហាទីម(عدي ابن حاتم) អំពីរឿងនយោបាយសង្គមកិច្ចរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام ។ លោកបានថា៖ "*ខ្ញុំបានឃើញថា នៅចំពោះមុខព្រះអង្គ صلوات الله عليه والسلام បុគ្គលមានអំណាចគ្រប់រូបទៅជាអន់ខ្សោយលុះគេបានវិនិច្ឆ័យឲ្យបុគ្គលនោះខុស ហើយបុគ្គលអន់ខ្សោយមានអំណាចលុះគេបានវិនិច្ឆ័យឲ្យខ្លួនត្រូវ ។*"

អ៊ីម៉ាំអាលី صلوات الله عليه والسلام មិនចាត់ទុកអំណាចជាធំទេ ។ សម្រាប់ព្រះអង្គ صلوات الله عليه والسلام "គ្រប់គ្រង" មិនមែនអ្វីដែលលើសពីការធ្វើឲ្យយុត្តិធម៌បានរាលដាលសុសសព្វនោះទេ ។ អាស្រ័យហេតុនេះឯងដែលព្រះអង្គ صلوات الله عليه والسلام ព្រមកាន់អំណាចនោះ ។

អ៊ីបនូ-អាប់បាស់បានតំណាលប្រាប់យើង កាលអ៊ីម៉ាំ صلوات الله عليه والسلام បានសួរលោកថា៖ "*តើស្បែកជើងនេះថ្លៃប៉ុន្មាន?*" ខណៈដែលព្រះអង្គ صلوات الله عليه والسلام កំពុងតែជួសជុលវា ។ អ៊ីបនូ-អាប់បាស់បានឆ្លើយថាវាមិនថ្លៃណាស់ណាទេ ។ អ៊ីម៉ាំ صلوات الله عليه والسلام មានវចនៈថា៖ "*សម្រាប់ខ្ញុំ ស្បែកជើងទាំងនេះមានតម្លៃជាងរដ្ឋបាលនិងអំណាចទៅទៀត ដែលគ្រាន់តែជាមធ្យោបាយសម្រាប់គាំទ្រច្បាប់ឬកម្ចាត់អំពើអយុត្តិធម៌ប៉ុណ្ណោះ ។*"

អ៊ីម៉ាំអាលី صلوات الله عليه والسلام បានអធិប្បាយនយោបាយសង្គមកិច្ចរបស់ព្រះអង្គ صلوات الله عليه والسلام យ៉ាងខ្លីថា៖ "*តើខ្ញុំអាចជាអ៊ីម៉ាំសម្រាប់មនុស្សបានទេ ដោយមិនចូលរួមក្នុងការឈឺចាប់របស់ពួកគេនិងភាពក្រីក្ររបស់ពួកគេទេនោះ?*"

## ២-ការលុបបំបាត់ឯកសិទ្ធិ

ចាប់តាំងពីឡើងកាន់អំណាចថ្ងៃដំបូងមកម្ល៉េះ អ៊ីម៉ាំអាលី صلوات الله عليه والسلام បានប្រកាសថាមូលដ្ឋាននយោបាយរបស់ព្រះអង្គ صلوات الله عليه والسلام គឺភាពស្មើគ្នារវាងមនុស្ស និងយុត្តិធម៌ ។ ជនជាតិអារ៉ាប់និងជនមិនមែនអារ៉ាប់មិនខុសគ្នាទេ វៀរលែងតែពាក់ព័ន្ធនឹងជំនឿ ។

នយោបាយចែកប្រាក់ជំនួយទ្រទ្រង់ស្មើគ្នារបស់ព្រះអង្គ صلوات الله عليه والسلام បានធ្វើឲ្យអស់បុគ្គលដែលធ្លាប់តែមានឯកសិទ្ធិក្នុងការចែកប្រាក់ជំនួយទ្រទ្រង់ក្នុងជំនាន់ខ៍លិហ្វបីមុននោះច្រួលច្របល់ ។

ពួកគេបានមកជួបព្រះអគ្គមហាប្រមុខរបស់អ្នកមានសទ្ធា صلوات الله عليه والسلام សូមឲ្យព្រះអង្គ صلوات الله عليه والسلام ត្រឡប់មករកនយោបាយចាស់វិញ ដោយសៀតសិកសម្ដីថាវាអាចនាំមកនូវជ័យជំនះលើសត្រូវរបស់ព្រះអង្គ صلوات الله عليه والسلام យ៉ាងងាយស្រួល ។ តែចម្លើយរបស់អ៊ីម៉ាំ صلوات الله عليه والسلام ម៉ឺងម៉ាត់ណាស់ គឺ៖ "*អស់លោកចង់ឲ្យខ្ញុំ صلوات الله عليه والسلام ស្វែងរកជ័យជំនះដោយវិធី*

*អយុត្តិធម៌មែនទេ?" បន្ទាប់មកព្រះអង្គ* صلوات الله عليه والسلام *មានវចនៈថា៖ "ប្រសិនបើប្រាក់នោះជារបស់ខ្ញុំ* صلوات الله عليه والسلام *ខ្ញុំ* صلوات الله عليه والسلام *នឹងចែកឲ្យគេស្មើៗគ្នា ។ តែបើប្រាក់នេះជារបស់អល់ឡោះហ៊ូ* عز جل*,វិញនោះ ឲ្យខ្ញុំថាអ្វី?"*



នយោបាយសង្គមកិច្ចរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام នេះ បាននាំមកលើរូបព្រះអង្គ صلوات الله عليه والسلام នូវទោសៈពីសំណាក់មេគណបក្សធំៗ និងពួកមេដឹកនាំកុលសម្ព័ន្ធដែលធ្លាប់តែបានទទួលប្រាក់ទ្រទ្រង់និងឯកសិទ្ធិពីខ័លិហ្វបីនាក់មុនៗ ដែលបានធ្វើឲ្យពួកគេបានក្លាយទៅជាអ្នកមានទ្រព្យធនលើសគេក្នុងឧបទ្វីបអារ៉ាប់ ។

នយោបាយនេះបានធ្វើឲ្យព្រះអង្គ صلوات الله عليه والسلام បាត់បង់ការគាំទ្ររបស់ជនជំនិតព្រះអង្គ صلوات الله عليه والسلام មួយចំនួន ។ រឿងរ៉ាវ

ពាក់ព័ន្ធនឹងបងប្រុសម្នាក់របស់ព្រះអង្គصلوات الله عليه والسلام ឈ្មោះអ៊ាគ៊ីល(عقيل) បានឆ្លុះបញ្ចាំងអំពីរឿងនេះគឺ៖

ថ្ងៃមួយអ៊ាគ៊ីល បងប្រុសរបស់អ៊ាលីصلوات الله عليه والسلامបានមកលេងព្រះអង្គصلوات الله عليه والسلام។ ពេលទទួលទានបាយ លោកបានភ្ញាក់ផ្អើលព្រោះតែមានតែនំបុ័ង ទឹកនិងអំបិលទេ។ លោកបានថា៖ "មិនមានអ្វីផ្សេងពីអ្វីដែលខ្ញុំឃើញនេះទេ?" អ៊ីម៉ាំصلوات الله عليه والسلامមានវចនៈថា៖ "សេចក្តីប្រោសប្រណីនៅលើអល់ឡោះហ្ចໍعزّ وجلّ, មែនទេ?" អ៊ាគ៊ីលបានសូមប្រាក់ពីអ៊ីម៉ាំអ៊ាលីصلوات الله عليه والسلامដើម្បីសងបំណុល។ អ៊ីម៉ាំصلوات الله عليه والسلامបានតបថា៖ "សូមរង់ចាំទាល់តែខ្ញុំបានទទួលប្រាក់បៀវត្សសិន។" អ៊ាគីលបានថា៖ "ឃ្លាំងប្រាក់នៅក្នុងដៃប្អូនឯងៗឲ្យបងចាំលុះបានទទួលបៀវត្ស?" អ៊ីម៉ាំصلوات الله عليه والسلامបានតបថា៖ "ខ្ញុំصلوات الله عليه والسلامមិនខុសពីមុស្លីមដទៃទេ។" អ៊ាគីលនៅតែទទូចសូម។ អ៊ីម៉ាំصلوات الله عليه والسلامបានប្រាប់គាត់ថា៖ "យល់ព្រមទេ យើងយកដាវទៅកាន់ស្រុកហ៊ីរ៉អ៊្ (ជិតស្រុកគូហ្វាស្ទ)។ នៅទីនោះមានអ្នកជំនួញមានៗច្រើននាក់។ យើងនឹងប្លន់ពួកគេយកទ្រព្យ។" អ៊ុគ៊ីលនិយាយដោយប្រមាថថា៖ "យើងមកនេះក្នុងឋានៈជាចោរឬ?" អ៊ីម៉ាំឌ៊ុំថមានវចនៈថា៖ "បងលួចមនុស្សម្នាក់ប្រសើរជាងលួចសហគមន៍មុស្លីមទាំងមូល។"

នេះគឺអ៊ីម៉ាំصلوات الله عليه والسلام។ ព្រះអង្គصلوات الله عليه والسلامរស់នៅជាជនក្រីក្រ ព្រះអង្គصلوات الله عليه والسلامបរិច្ចាគទ្រព្យ។ កាលណាមានគេថាមូអ៊ាវីយ៉ាស៊ូ បុគ្គលបះបោរ ចាយវាយទ្រព្យយ៉ាងច្រើននិងសំណូកដើម្បីទិញជ័យជំនះ ហើយអ៊ីម៉ាំصلوات الله عليه والسلامគប្បីធ្វើដូច្នេះដែរ កាលនោះអ៊ីម៉ាំصلوات الله عليه والسلامរំលឹកពួកគេដោយសុភាសិតរបស់ព្រះអង្គصلوات الله عليه والسلامថា៖ "*ចូរកុំស្វែងរកជ័យជំនះដោយវិធីអយុត្តិធម៌ជាដាច់ខាត ។*"

នេះគឺនយោបាយសង្គមកិច្ចរបស់បុគ្គលដែលមានសទ្ធាជ្រះថ្លា លើសអស់បុគ្គលដែលមានសទ្ធាជ្រះថ្លា ព្រះអគ្គមហាប្រមុខរបស់អ្នកមានសទ្ធាទាំងពួង អ៊ាលីصلوات الله عليه والسلام ៕

## សម្រង់ព្រះវចនៈត្រចះត្រចង់

-ចូរកុំរស់ដើម្បីហូប តែចូរហូបដើម្បីរស់។

-មរណភាពរបស់ជនពាលមានប្រយោជន៍ទូទៅ។

-ចូរកុំជេរប្រទេចមារឲ្យអ្នកផងឃើញ ខណៈដែលខ្លួនឯងជាមិត្តរបស់វាដោយលាក់បាំង។

-មូលហេតុរបស់អ្នកនិពន្ធនៅលើស្លាបប៉ាកកា។

-មិត្តជាផ្នែកមួយនៃអារម្មណ៍ បងប្អូនជាផ្នែកមួយនៃបេះដូង។

-ចូរកុំថាអ្វីដែលខ្លួនមិនចង់ឲ្យគេថាមកលើខ្លួន។

-សេចក្តីឥតគួរសមជាដើមហេតុនៃសេចក្តីអាក្រក់។

-ចូរសិក្សាចំណេះវិជ្ជាពេលនៅក្មេងវ័យ វានឹងធ្វើឲ្យស្ទាត់ជំនាញពេលមានវ័យចំនាស់។

-ចូរជ្រើសយកចុះចាញ់ខណៈដែលអ្នកមានយុត្តិធម៌ក្នុងខ្លួន។ ចូរកុំជ្រើសយកឈ្នះខណៈដែលអ្នកមានអយុត្តិធម៌ក្នុងខ្លួន។

## អត្តសញ្ញាណរបស់អ៊ីម៉ាំ صلوات الله عليه والسلام

-នាម ៖ អាលី

-នាមល្បីល្បាញ ៖ ព្រះអគ្គមហាប្រមុខ

-នាមគោរព ៖ អាប៊ូ អាល់-ហាសាន់

-ថ្ងៃកើត ៖ ២៣ឆ្នាំមុនសករាជហ៊ីច្រ៉ោះត៍ ថ្ងៃទី ១៣ ខែរ៉យ៉ាប់

-ថ្ងៃឡើងកាន់ខ៏លីហ្វាស់ ៖ ឆ្នាំទី៣៥នៃសករាជហ៊ីច្រ៉ោះត៍

-កាលបរិច្ឆេទកាន់ខ៏លីហ្វាស់ ៖ ៥ ឆ្នាំ

-ថ្ងៃទទួលទុក្ករៈកម្ម ៖ ថ្ងៃទី ២១ ខែរ៉ម៉ាដូន ឆ្នាំទី៤០នៃសករាជហ៊ីច្រ៉ោះត៍

